# ជីវិត

Life

ចេញផ្សាយលេខ៖ ៤៩

ភូមិភាគភ្នំពេញ ខែតុលា ឆ្នាំ២០១៧

ព្រឹត្តិបត្រព័ត៌មានពីព្រះសហគមន៍កាតូលិក

ឆ្នាំគ្រួសារ

THE YEAR OF FAMILY

CARITAS CHRISTI URGET NOS

# អបអរសាទរគម្រប់ខួប ២៥ ឆ្នាំ ព្រះសហំគមន៍សន្តយ៉ូសែប ផ្សារតូច



# ព្រះគម្ពីរដ៏អស្ចារ្យ
# ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជារតនសម្បត្តិរបស់ខ្ញុំ !



ហេតុការណ៍នេះបានកើតឡើងកាលពីម្ភៃឆ្នាំមុន នៅក្នុងភូមិនេសាទកាតូលិកមួយ នៅតំបន់បុំបៃនៃប្រទេសឥណ្ឌា។ ប្អូនប្រុសរបស់បងស្រី Blanchi ដែលជាសមាជិកនៃគ្រួសារព្រះនាងម៉ារីជាទីពំនឹងពំនាក់ (FMA) បានកំពុងរៀបចំខ្លួនដើម្បីរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែពីរបីថ្ងៃមុនរៀបអាពាហ៍ពិពាហ៍ គាត់បានសម្រេចចិត្តចេញទៅនេសាទ ជាមួយអ្នកនេសាទប្រាំពីរនាក់ផ្សេងទៀត។ អាកាសធាតុល្អ ឧបករណ៍នេសាទ ព្រមទាំងម្ហូបអាហារសម្រាប់រយៈពេលពីរថ្ងៃបានរៀបចំទុកដាក់ក្នុងទូករួចជាស្រេច។ បន្ទាប់ពីចេញដំណើរអស់រយៈពេល ៤ម៉ោងកន្លះ ពួកគេបានទៅដល់តំបន់ទឹកជ្រៅ ហើយគេក៏បានចាប់ផ្តើមទម្លាក់អួនរបស់គេចុះទៅក្នុងទឹក។ ពេលនោះម៉ោងជិត៧ហើយ មេឃក៏កាន់តែងងឹតទៅ និងជាពេលដែលគេត្រូវទទួលទានអាហារល្ងាច មុនពេលគេសាអួនដាក់ទូកវិញនាពេលប្រមាណពាក់កណ្តាលអាធ្រាត្រ។

តាមទម្លាប់ដែលគេធ្វើរាល់ល្ងាចមុនពេលទទួលទានអាហារ គេបើកព្រះគម្ពីរដោយបិទភ្នែក និងគេអានខគម្ពីរនោះជាខគម្ពីរដែលព្រះវិញ្ញាណដ៏វិសុទ្ធបានប្រទានឲ្យពួកគេ។ បន្ទាប់មក ពួកគេបានដាក់ព្រះបន្ទូលដ៏មានតម្លៃរបស់ព្រះជាម្ចាស់ក្នុងក្រណាត់សមួយ។ រំពេចនោះស្រាប់តែមានពន្លឺដ៏ខ្លាំងមួយចាំងមកលើពួកគេ។ ទូកដ៏ធំមួយបានមកបុកពន្លិចទូកដ៏តូចរបស់ពួកគេ។ យឺតពេលហើយក្នុងការគេចចេញពីគ្រោះថ្នាក់នេះ ទូករបស់ពួកគេបានដាច់ជាពីរ ហើយអ្នកនេសាទទាំងប្រាំបីនាក់បានរសាត់ទៅក្នុងសមុទ្រដែលងងឹតឈឹង។

ពួកគេខំប្រឹងហែលហើយ ហែលទៀត។ គេបានឃើញពន្លឺដ៏តូចមួយនៅពីចម្ងាយ ហើយគេបានប្រើកម្លាំងដែលមានទាំងប៉ុន្មាន ហែលសំដៅទូកមួយដែលមានអ្នកនេសាទជាអ្នកកាន់សាសនាហិណ្ឌូ។ ពួកគេបានសង្គ្រោះឡើងពីទឹក។

នៅព្រឹកបន្ទាប់ ពេលដែលព្រះអាទិត្យរះ គេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ខណៈគេបានឃើញព្រះគម្ពីរស្ថិតនៅក្នុងក្រណាត់ពណ៌សនោះ អណ្តែតក្បែរទូកដែលបានសង្គ្រោះពួកគេ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានអមដំណើរពួកគេថែរក្សាគេពួកគេពេញមួយយប់ដ៏រន្ធត់នោះ។

ឱព្រះអម្ចាស់អើយ! ព្រះបន្ទូលរបស់ព្រះអង្គគឺជាជីវិត ព្រះបន្ទូលព្រះអង្គជារតនសម្បត្តិដែលណែនាំខ្ញុំ ដែលការពារខ្ញុំ ដែលអមដំណើរខ្ញុំក្នុងពេលមានអំណរសប្បាយ និង ពេលមានទុក្ខព្រួយ នៃដំណើរជីវិតរបស់ខ្ញុំ។ ព្រះបន្ទូលព្រះអង្គជាជីវិត។ សូមអរព្រះគុណព្រះអង្គជាព្រះអម្ចាស់ ចំពោះអាហារនេះ ដែលព្រះអង្គប្រទានមកខ្ញុំរាល់ថ្ងៃ។

អត្ថបទដោយលោកអភិបាលព្រះសហគមន៍ អូលីវីយេ ដោយផ្តើមចេញពីហេតុការណ៍ដ៏ពិតប្រាកដជាសក្ខីភាពរបស់បងស្រី Blanchi ជាបងស្រីនៅក្នុងក្រុមគ្រួសារ សាឡេស៊ាន ភ្នំពេញប្រទេសកម្ពុជា ។ នោះក្រុមគ្រួសារប្អូនប្រុសរបស់បងស្រីបានអនុញ្ញាតឲ្យបងស្រីខ្ចី ព្រះគម្ពីរដ៏អស្ចារ្យ" នោះ សម្រាប់ពិធីបុណ្យ ២៥ ឆ្នាំ នៃវត្តមានរបស់ក្រុមបងស្រីសាឡេស៊ាន នៅប្រទេសកម្ពុជា។

# THE MIRACULOUS BIBLE

# THE WORD OF GOD, MY TREASURE !

It was twenty years ago, in a Catholic fishing village in the Bombay region of India.

The younger brother of Sister Blanchi, FMA, was preparing to marry. But a few days before his marriage, he decided to go fishing with seven other fishermen. The day was beautiful, and fishing nets and food for two days at sea were loaded onto the boat. After cruising for four and a half hours, they arrived in deep water and began to lower their nets. It was already almost 7:00 PM. Night fell and it was time to eat before going to retrieve the nets around midnight.

As they did every evening before dinner, they opened the Bible at random and read the verse that the Holy Spirit offered them. Then they put the precious Word of God on a white cloth.

Suddenly a strong light dazzled them: an enormous boat was bearing down on their little craft. It was too late to escape and their boat was split in two and the eight fishermen found themselves in the black waters.

Swim, swim! They saw a small light in the distance and used their last strength to swim to a boat manned by Hindu fishermen. They were saved!

The next morning at the rising of the sun, how great was their surprise when they saw floating beside the boat that had saved them their BIBLE in its white cloth!!!! The Word of God had accompanied them and protected them all through this dramatic night!

Your Word, O Lord, is Life. It is my treasure that guides me, protects me, and accompanies me in the joys and sorrows of my Life. Your Word is Life! Thank you, Lord, for this food you offer me every day.

By Bishop Olivier, from the true story of Sister Blanchi, a Salesian sister in Phnom Penh, Cambodia. Her brother's family allowed her to borrow this "Miraculous Bible" for the celebration of 25 years of the presence of the Salesian Sisters in Cambodia.





# គ្រីស្តបរិស័ទ១៨និកាយទទួលអាហារសាមគ្គីរួមគ្នា ដើម្បីមិត្តភាព និងសុខដុមនីយកម្ម អន្តរនិកាយ



រូបជុំគ្នាតំណាងគ្រីស្តបរិស័ទទាំង១៨ និកាយ

ក្រុមប្រឹក្សានៃក្រុជំនុំ ក្រុមប្រឹក្សានៃព្រះវិហារ សហគមន៍គ្រីស្តបរិស័ទ ព្រះសហគមន៍កាតូលិក និង សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ចំនួន១៨ ក្រុម បានមកជួបជុំ គ្នាទទួលអាហារសាមគ្គីរួមគ្នាដើម្បីមិត្តភាព និង សុខដុមនីយកម្ម អន្តរនិកាយ។ ពិធីនេះប្រព្រឹត្តទៅកាលពីថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៧ នៅសណ្ឋាគារ ហ្គាឌែនស៊ុធីភ្នំពេញ ក្រោមអធិបតីរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។

លោកអេដវើត ដោវ តំណាងសាសនាចក្រនៃព្រះយេស៊ូគ្រីស្ត នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ក្នុងនាមអ្នករៀបចំកម្មវិធីបានថ្លែងថា លោកសូមស្វាគមន៍ បងប្អូនទាំងអស់ ដោយរីករាយដែលមកជួបជុំគ្នានៅថ្ងៃនេះ។ លោកក៏អរគុណ ចំពោះការគាំទ្ររបស់ថ្នាក់ដឹកនាំក្រសួងធម្មការ និងសាសនា លើកិច្ចការនានាដើម្បីសុខដុមរមនានៅកម្ពុជា។ លោកថាគោលបំណងនៃការជួបជុំនៅថ្ងៃនេះគឺ ទទួលអាហាររួមគ្នា ចែករំលែក សេចក្តីស្រឡាញ់ស្គាល់គ្នាកាន់តែជិតស្និទ្ធ និងជួយជ្រោមជ្រែងគ្នាទៅវិញទៅមក។

កិច្ចសន្ទនានានាជាអន្តរនិកាយនៃគ្រីស្តបរិស័ទនៅកម្ពុជាតែងប្រារព្ធធ្វើឡើងក្នុងទម្រង់ផ្សេងៗគ្នា។ ក្នុងនោះក៏មានការជួបផ្ទាល់សំណេះសំណាល រវាងសម្តេចតេជោ ហ៊ុន សែន នាយក-រដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជាផងដែរ។

មានប្រសាសន៍ ក្នុងឱកាស នោះ ឯកឧត្តមទេសរដ្ឋមន្ត្រី ហ៊ឹម ឆែម រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា បានលើកឡើងថា គ្រប់ព្រះនៃសាសនា ទាំងអស់សុទ្ធតែជួយឲ្យមនុស្ស រស់នៅក្នុងសន្តិភាព សុខដុមនីយកម្ម នៅលើផែនដីនេះ។

ឯកឧត្តម បន្តថា នៅថ្ងៃនេះយើងជួបជុំគ្នានៅទីនេះមិនមែនត្រឹមតែទទួលទានអាហារនោះទេ តែដើម្បីកសាងសន្តិភាពសុខដុមនីយកម្ម តាមការប្រៀនប្រដៅរបស់ព្រះយេស៊ូ ជាព្រះរបស់បងប្អូន។ ក្នុងលោកយើងនេះ មនុស្សអ្នកជឿទាំងអស់ស្រឡាញ់សន្តិភាព គ្មានអ្វីប្រសើរជាងសន្តិភាពទេ។ កម្ពុជាមានបទពិសោធន៍សង្គ្រាម យ៉ាងជូរចត់ហើយ គ្មានទេពេលវេលាជួបជុំគ្នាដូចថ្ងៃនេះ។

ឯកឧត្តម ហ៊ឹម ឆែម ក៏បានអធិដ្ឋានបួងសួងដល់ព្រះយេស៊ូ សូមឲ្យយើងទាំងអស់គ្នាបានពោរពេញដោយសន្តិភាព។ ចេះស្រឡាញ់រាប់អានគ្នា និងរួមគ្នារក្សាសន្តិភាព និងសុខដុមនីយកម្មនៅកម្ពុជា។

## Denominations have Fellowship Meal for Harmonisation

On 27 September eighteen members from the protestant churches, the Catholic Church, and the Church of Jesus Christ of Latter-day Saints gathered togetherto have a fellowship meal for harmonization of the denominations. The main guest of honour was His Excellency Senior Minister Him Chhem of the Ministry of Cult and Religion.

In his opening welcoming speech, Mr. Edword Daov, a representative of the Church of Jesus Christ of Latter-day Saints praised the leadership of the Ministry of Cult and Religion for religious harmonyy in Cambodia. The representative said that the purpose of the gathering was to have a fellowship meal, to demonstrate love, and was an opportunity to get to know each other better and to support each other.

Inter-religious dialogue in Cambodia has always been held under various guises including a face-to-face meeting with Premier Hun Sen . His Excellency Him Chhem said that religions help people live in peace and harmony. He went on to say: “Today’s gathering is not only a meal but an opportunity also, for the promotion of peace and harmony as taught by Jesus, your God. In our world, those who believe love peace. Nothing is better than peace. Cambodia had experienced a bitter civil war, and there had been little or no opportunity for a meeting such as today.”

His Excellency also prayed to Jesus saying: “May all of us be filled with peace. May we love, be friendly with one another, and unite to maintain peace and harmony in Cambodia.”


គ្រីស្តបរិស័ទនៅអរីយក្សត្រទទួលអគ្គសញ្ញាលាបថ្ងាសពីលោកអភិបាល។ រូបថត សុវណ្ណភូមិ

## គ្រីស្តបរិស័ទ២៦នាក់ ទទួលអគ្គសញ្ញាលាបថ្ងាស នៅព្រះវិហារ ព្រះមាតានៃសន្តិភាព

បេក្ខជន បេក្ខនារីចំនួន២៦នាក់មកពី ព្រះវិហារព្រះមាតានៃសន្តិភាព (អរិយក្សត្រ) ព្រះវិហារ សន្តសិលា(ពោធិ៍ធំ) ព្រះវិហារ សន្តយ៉ូសែប (ក្តីកណ្តាល) និង ព្រះវិហារសន្តីម៉ារី (តួតាំង) បាន ទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីផ្តល់កម្លាំងក្នុងការចេញទៅប្រកាស ដំណឹងល្អ កាលពីថ្ងៃទី២៩ តុលា ២០១៧ នៅព្រះវិហារព្រះមាតា នៃសន្តិភាព (អរិយក្សត្រ) ដោយមានលោក អូលីវីយេ ឆ្មីតអឺស្លែរ ជាអធិបតី និងមានបងប្អូន គ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។

លោកអូលីវីយេ បានមានប្រសាសន៍ថា៖ នេះជាថ្ងៃចុងក្រោយ សម្រាប់ឆ្នាំនេះ ក្នុងការធ្វើអគ្គសញ្ញាលាបថ្ងាស ហើយគឺជាឱកាស មួយដើម្បីជួបជាមួយគ្រីស្តបរិស័ទ ជួបជាមួយបេក្ខជនផ្ទាល់ និង ក៏ជាឱកាសដើម្បីផ្តល់កម្លាំងដល់ព្រះសហគមន៍ផងដែរ។

លោកបានរំឭកថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជួយ៖ ១) ណែនាំឲ្យយើងទទួលអំណរសប្បាយ ដោយស្តាប់ព្រះបន្ទូលរបស់ ព្រះជាម្ចាស់ ។ ២)ណែនាំឲ្យយើងទៅជាគ្រីស្តបរិស័ទដែលទទួល ខុសត្រូវខ្ពស់ ដើម្បីធ្វើជាគំរូដល់បងប្អូនឯទៀតៗ រួមទាំងបងប្អូន ដែលជាគ្រីស្តបរិស័ទដែលលែងបានចូលព្រះវិហារ និងបងប្អូន ដែលមិនទាន់ស្គាល់ព្រះយេស៊ូ។៣)ត្រូវស្រឡាញ់ព្រះជាម្ចាស់ អស់ពីដួងចិត្ត អស់ពីប្រាជ្ញា និងអស់ពីកម្លាំងរបស់ពួកយើង និង ស្រឡាញ់បងប្អូនឯទៀតៗដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ។ លោកថាទាំងនេះជាគោលដៅសម្រាប់ជីវិតយើង ដោយដឹងថា ព្រះសហគមន៍មានជីវិត និងរីកចម្រើនប្រសិនបើយើងយកចិត្ត ទុកដាក់ប្រតិបត្តិតាមព្រះ អំណោយទានដែលយើងទទួលតាម រយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ សម្រាប់បងប្អូនថ្មីត្រូវចេញសកម្មភាព ធ្វើជាគំរូ ដល់បងប្អូនឯទៀតៗ ត្រូវអធិដ្ឋាន បម្រើ និងស្រឡាញ់។

បន្ទាប់ពីធម្មទេសនាលោកអភិបាល បានសួរបញ្ជាក់អំពីជំនឿ របស់បេក្ខជនចំពោះ ព្រះជាម្ចាស់នៅក្នុងពិធីទទួលអគ្គសញ្ញាលាប ថ្ងាស និងប្រកាសធម៌ជឿរួមជាមួយគ្រីស្តបរិស័ទទាំងអស់ រួចទូល អង្វរព្រះជាម្ចាស់រួមជាមួយសន្តបុគ្គលទាំងអស់ដើម្បីសូមព្រះ វិញ្ញាណយាងមកគង់សណ្ឋិតជាមួយបេក្ខជនទាំងនោះ ដើម្បី ឲ្យពួកគេទទួលបានផលផ្លែនៃព្រះវិញ្ញាណ។ សរសេរដោយ ដាលីស

## Twenty Six Candidates Confirmed

Twenty six candidates from the Queen of Peace church in Areyksat, the church of Sts. Peter and Paul in Pothom, St. Joseph's church in Kdey Kandal and St. Mary's church in Toutaing received the Sacrament of Confirmation. The Sacrament of confirmation is a source of strength to go out and proclaim the Good News of the Gospel. It took place on 29 October 2017, which was celebrated by Bishop Olivier Schmittaeusler with a good number of Catholics attending.

In his homily, Bishop Olivier said that this was the last day for this year's confirmation to be celebrated and it was the opportunity to meet with the faithful, the candidates in person. It's also the chance to provide the Church with strength. "Upon visiting the pastoral sector, I have reminded the faithful that the Holy Spirit came not only on the brothers and sisters who receive the sacrament, but also on all of us in order to take high responsibility for the life of the Church."

His Excellency Bishop Olivier also put emphasis on the fruit of the Holy Spirit, especially the Spirit of love, faith, peace and patience, which lead us to create a society into the Church.

Bishop Olivier reminded them present with mention of the help of the Word of God.

"First, it guides us to receive the joy by listening to the Word of God. Second, it leads us to become the faithful to be highly responsible for setting an example for others to follow and brothers and sisters who no longer enter the church and they have yet to know Jesus. Third, you have to love God with all of heart, with all of mind and with all of our strength and you love others just as Jesus loved us as well."

Bishop Olivier said: "This is the goal for us knowing that the Church has life and progress should we focus our mind on operating in accordance with the Gift of God we received through the Holy Spirit. For the new candidates, you have to carry out actions to set an example for others to follow. You have to pray, serve and love them."

Following the homily, Bishop Oliver asked the candidate questions about their faith in God at the confirmation rite. They then professed the Creed together with the faithful and petitioned God with all Saints in order for the Holy Spirit to come on the candidates so that they will receive the fruit of the Holy Spirit.

# កុមាររៀនអំពីរបៀបរស់នៅ ពីកម្មវិធីបោះជំរំ នៅផ្សារតូច



លោកបូជាចារ្យផ្ដល់ការអប់រំដល់ក្មេងៗក្នុងកម្មវិធីបោះជំរំ។ រូបថត លីហៀង

កុមារចំនួន៨៤នាក់ ដែលមានពីអាយុ៨ឆ្នាំ ដល់១៣ឆ្នាំ មកពីព្រះសហគមន៍កាតូលិកផ្សារតូច អរិយក្សត្រ ព្រែកតាទែន សែនសុខ និងគីឡូលេខ១១ បានចូលរួមក្នុងកម្មវិធីបោះជំរំកុមារនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច ក្រោមប្រធានបទ "កូនល្អ សិស្សល្អ និងមិត្តល្អ"។ កម្មវិធីនេះប្រព្រឹត្តឡើងចាប់ពីថ្ងៃទី០៧ ដល់១០ កញ្ញា ២០១៧ ក្រោមការដឹកនាំដោយលោកបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញខាងជើង ប៉ូល រឿង ឆ័ត្រសិរី។

តាមប្រសាសន៍របស់លោកបូជាចារ្យឆ័ត្រសិរី បានឲ្យដឹងថា ការបោះជំរំ គឺជាការអប់រំទាំងយុវជន និងកុមារ ដោយយុវជនអាចចាត់ចែង និងគ្រប់គ្រងក្នុងការរៀបចំកម្មវិធីសម្រាប់មណ្ឌលសកម្មភាពភ្នំពេញខាងជើង។ លោកបន្តថា បានឃើញយុវជនបើកចិត្តទូលាយក្នុងការសហការគ្នាដូចអ្វីដែលលោកបានស្នើ គឺការលះបង់ភាពអាត្មានិយម មានទំនួលខុសត្រូវ និងចេះយល់ចិត្តអធ្យាស្រ័យដល់គ្នា។

លោកបូជាចារ្យបញ្ជាក់ថា៖ សារៈសំខាន់នៃប្រធានបទនេះ គឺការអប់រំនៅក្នុងព្រះសហគមន៍ព្រោះយើងមានព្រះយេស៊ូជាព្រះគ្រូ ហើយយើងគឺជាសិស្ស មិនតែប៉ុណ្ណោះយើងមានព្រះបិតាជាឪពុកដ៏ល្អ និងយើងគឺជាកូន ព្រមទាំងយើងមានព្រះយេស៊ូដែលមិនបានចាត់ទុកយើងជាអ្នកបម្រើតែជាមិត្តសម្លាញ់របស់ព្រះអង្គ។

កុមារីមកពីព្រះសហគមន៍ផ្សារតូច ពេជ្រ ចាន់ពិដោរ បានឲ្យរៀបរាប់ថា នេះជាលើកដំបូងដែលបានចូលរួមកម្មវិធីបោះជំរំ ហើយរយៈពេលប៉ុន្មានថ្ងៃមកនេះ។

បានយល់ច្រើនអំពីប្រធានបទ កូនល្អត្រូវចេះស្ដាប់បង្គាប់ឪពុកម្ដាយ មិត្តល្អត្រូវចេះជួយគ្នា សាមគ្គីគ្នា និងចេះណែនាំគ្នាឲ្យធ្វើទង្វើល្អសម្រាប់សង្គម ចំណែកឯសិស្សល្អត្រូវចេះស្ដាប់បង្គាប់គ្រូដែលជាមាតាបិតាទីពីររបស់យើង។

ដោយដាលីស

## Children Learn How to Live in Camp Experience

Eighty four children between 8 and 13 years of age from the Churches of Phsar Toich, Areyksat, Sen Sok and Kilometer 11 gathered to participate in a camp. The camp was organized at St. Joseph's parish in Phsar Touch with the theme "Good Children, Good Students and Good Friends." The camp took place from 7 to 10 September 2017 and it was headed and faciliated by Fr. Roeung Chhat Sirey, the priest in charge of the pastoral sector in northern Phnom Penh.

Fr. Chhat Sirey said that the camp was intended to educate both children and youth with the representatives of the youth managing and coordinating the programme for the northen Phnom Penh pastoral sector. The priest continued by saying that he had seen the youth open their heart wide in cooperating with what he had proposed, namely: the abandoning of selfishness, irresponsbility, misunderstandings and to have a forgiving heart.

As for the children, the local Church chose the topic for them with the aim of helping them with better understading the way of life in family and in relatinships in society alike. The priest added that because the family is the basic foundation of the Church, the needs of people in the Year of the Family of the Apostolic Vicariate of Phnom Penh was to help the children know about what they need to do in the family and in society.

Fr. Chhat Sirey emphasised: "The importance of the topic is education in the Church because we have Jesus as the Great Master and we are the students. We have not only the Father as a good father and we are the children but also we have Jesus, who did not consider us His servants but His friends."

Pich Chanpidau from the Church in Phsar Toich said that this was the first time that she had participated in the camp and some showed much interest in prayers, games, the story of Jesus and relationships with one another.

Pich Chanpidau have understood more about the topic. She said: " A good child has to be obedient to his/her parents. A good friend has to help each other with solidarity and he/she even leads one another to do good deeds in society. A good student has to obey his/her teacher, who are our second parents."



និស្សិតជំនាន់ទី៣ នៃសាលាអប់រំជំនឿសន្តយ៉ូស្ទីន

## អ្នកណាស្តាប់ព្រះបន្ទូលហើយអនុវត្តតាម អ្នកនោះមានសុភមង្គលហើយ (បើកឆ្នាំសិក្សាសាលាសន្តយ៉ូស្ទីន)

"អ្នកណាស្តាប់ព្រះបន្ទូលហើយអនុវត្តតាម អ្នកនោះមានសុភមង្គលហើយ" នេះជាប្រសាសន៍របស់លោកអូលីវីយេ ក្នុងធម្មទេសនា នៃអភិបូជាបើកឆ្នាំសិក្សាថ្មី ២០១៧-២០១៨ នៃសាលា អប់រំជំនឿសន្ត យ៉ូស្ទីន ឆ្នាំទីពីរ ជំនាន់ទី៣ កាលពីថ្ងៃទី១៤ តុលា ២០១៨ នៅព្រះវិហារសន្តសិលា និងសន្តប៉ូលភ្នំពេញថ្មី ដោយមាននិស្សិត និងលោកបូជាចារ្យ ដែលជាសាស្ត្រាចារ្យតាមមុខវិទ្យានានាចូលរួមជាច្រើនកុះករ។

ក្នុងឱកាសនេះផងដែរ លោកអភិបាល បានពន្យល់ណែនាំគ្រីស្តបរិស័ទដែលជានិស្សិតទាំងអស់ ឲ្យយកចិត្តទុកដាក់ស្តាប់ និងអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដោយលោកបានលើកឡើងនូវកម្មវិធីសិក្សានានារបស់សាលាសន្តយ៉ូស្ទីន សុទ្ធតែជាវិធីក្នុងការស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ដូចជាសីលធម៌ព្រះសហគមន៍ ប្រវត្តិសាស្ត្រព្រះសហគមន៍ អភិបូជាជារៀងរាល់ព្រឹក និងរបៀបរស់នៅជាក្រុមជាដើម។ល។

លោកអូលីវីយេ បញ្ជាក់ទៀតថា ក្នុងឆ្នាំសិក្សាថ្មីនេះ ជាពេលដែលយើងត្រូវយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលបន្ថែមទៀតដើម្បី៖ ១) ឲ្យខ្លួនយើងម្នាក់ៗនិងសាលារបស់យើងមានជីវិតរីកចម្រើនថែមទៀត និងជាពិសេសតាមរយៈទំនាក់ទំនងរបស់បងប្អូន។ ២) ឲ្យអ្នកឯទៀតៗនៅជុំវិញ អាចស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានដែរ ជាពិសេសតាមរយៈបណ្តាញសង្គមសម័យទំនើប។ ៣) យកចិត្តទុកដាក់ចំពោះក្រុមពន្លកថ្មី ដែលទើបតែទទួលអគ្គសញ្ញាជ្រមុជទឹក និងជួយឲ្យយុវជន យុវនារីយល់អំពីតម្លៃជីវិតនៃការត្រាស់ហៅហើយក្លាហានដើម្បីឆ្លើយតបចំពោះការត្រាស់ហៅនោះ។

សាលាអប់រំជំនឿ សន្ត យ៉ូស្ទីន បានបង្កើតឡើងនៅចុងឆ្នាំ២០១១ ដោយលោកអភិបាលអូលីវីយេ ជ្មីតអឺស្លែរ ដោយមាន ព្រះគម្ពីរវិទ្យា ប្រវត្តិសាស្ត្រព្រះសហគមន៍ ជីវិតខាងផ្លូវវិញ្ញាណ ទេវវិទ្យា គោលលទ្ធិគ្រីស្តសាសនាតាមព្រះសហគមន៍កាតូលិក សីលធម៌ព្រះសគមន៍កាតូលិក ព្រមទាំងមានកម្មវិធីរិះគិតអំពីសង្គមតាមរយៈវាគ្មិននានា ជាពិសេសសាលាបានផ្តល់ឱកាសឲ្យនិស្សិតបានចុះកម្មសិក្សា ដើម្បីឈ្វេងយល់អំពីជីវិតព្រះសហគមន៍នៅតាមបណ្តាប្រទេសមួយចំនួនផងដែរ។

ដោយ ដាលីស

**"Blessed rather are those who hear the word of God and obey it!"**

This is the phrase quoted from the Bible by Bishop Olivier Schmittaeusler in his homily. Bishop Olivier also quoted it on the occasion of the opening the new academic year 2017-2018 for the third batch of the students at St. Justin's School of Faith on 14 October 2017. The ceremony took place at the parish of Sts. Peter and Paul in Phnom Penh Thmei, which was attended by many professorial priests and students.

Bishop Olivier urged all students to pay attention to and put into practice the Word of God in their daily lives. He said that all study programmes of the school were to reflect the Word of God in day-to-day life such as ethics , Church history, morning Mass, the way of living in groups etc.

His Excellency Bishop Olivier emphasised: "This year is the time when we have to heed the Word of God further:

"First, it enables each one of us, and our school, to have a progressive life especially through relationships with our brothers and sisters. Second, it allows other people around to be able listen to the Word of God, especially on social media. Third, we care for neophytes, who have just been baptized to better understand of the values of vocation and the courage to answer that call."

Miss Vann Nychhay Eng, an outstanding student of the school said that St. Justin's School of Faith had been a great help to her in understanding more about the tenets of Christianity, especially helping her with new ideas to educate children. The student added that one of the subjects she likes is spirituality because the subject is about life and a relationship with others and God.

St. Justin's School of Faith was established in the year 2011 by Bishop Olivier Schmittaeulser. The school teaches Scripture, church history, spirituality, Theology, the teachings of the Catholic Church, and ethics. The school also has a programme reflecting on social developments and events with guest speakers. The school has also provided the students an opportunity to learn about and understand the pastoral life of the Catholic Church in other countries as well.

# ការយកចិត្តទុកដាក់លើកុមារតាមរយៈកម្មវិធីកាយឫទ្ធិ



មេក្រុមកាយរិទ្ធិមួយចំនួនតាមព្រះសហគមន៍។ រូបថត សុវណ្ណភូមិ

ក្រុងព្រះសីហនុ៖ "ជោគជ័យរបស់ខ្ញុំ" គឺជាប្រធានបទសម្រាប់កម្មវិធីបោះជំរំ មេក្រុមកាយឫទ្ធិនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលរៀបចំដោយការិយាល័យយុវជន ជំទង់ និងកុមារ ភូមិភាគភ្នំពេញ។ កម្មវិធីបោះជំរំនេះបានប្រព្រឹត្តទៅរយៈពេលបីថ្ងៃគឺពីថ្ងៃទី២៩ កញ្ញា ដល់ថ្ងៃទី០១ តុលា ឆ្នាំ២០១៧ នៅព្រះសហគមន៍សន្តមីកាអែលក្រុងព្រះសីហនុ ដោយមានមេក្រុមកាយឫទ្ធិចូលរួមប្រមាណជាង២០០នាក់។

នៅក្នុងធម្មទេសនានៃអភិបូជាបិទកម្មវិធីបោះជំរំមេក្រុមកាយឫទ្ធិ លោកបូជាចារ្យ អ៊ុន សុន បានផ្ដាំផ្ញើដល់មេក្រុមកាយឫទ្ធិទាំងអស់ថាត្រូវខិតខំអនុវត្ត ឲ្យបានច្រើនជាងទ្រឹស្ដី។ លោកថា "សូមឲ្យយើងទាំងអស់គ្នាត្រូវពូកែធ្វើ ជាងពូកែនិយាយ"។ លោកបន្តថា "ប្រសិនបើគ្មានការអនុវត្តន៍គឺគ្មានផលផ្លែនោះទេ សូមកុំធ្វើនូវអ្វីៗដែលអ្នកដទៃធ្វើសម្រាប់អ្នក ប៉ុន្តែចូរធ្វើអ្វីៗដែលព្រះជាម្ចាស់ធ្វើសម្រាប់អ្នក ហើយមេក្រុមកាយឫទ្ធិទាំងអស់ត្រូវតែយកចិត្តទុកដាក់លើកុមារ តាមរយៈកម្មវិធីកាយឫទ្ធិ"។

លោក ស៊ាន់ សារឿន ជាអ្នកសម្របសម្រួលកម្មវិធីបោះជំរំកាយឫទ្ធិក្នុងភូមិភាគភ្នំពេញ បានថ្លែងថា នេះជាពេលវេលាដែលមេក្រុមកាយឫទ្ធិទាំងអស់ទទួលការអប់រំបន្ថែម និងទទួលប្រធានបទថ្មី ទៅអនុវត្តតាមព្រះសហគមន៍របស់ពួកគេ ព្រមទាំងបន្តជួយកុមារកាយឫទ្ធិដែលត្រូវការយើង ជាពិសេសកុមារដែលមិនសូវមានអ្នកយកចិត្តទុកដាក់ កុមារដែលគាត់ទំនេរ នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ។

មេក្រុមកាយឫទ្ធិ ទាំងប្រាំបួនមណ្ឌលសកម្មភាពក្នុងភូមិភាគភ្នំពេញ បានថ្លែងស្រដៀងគ្នាថា រយៈពេលបីថ្ងៃនៃកម្មវិធីបោះជំរំមេក្រុមកាយឫទ្ធិនេះ ពួកគេរៀនបានច្រើនអំពីប្រធានបទ "ជោគជ័យរបស់ខ្ញុំ" ដោយបានទទួលនូវរបៀបណែនាំកុមារកាយឫទ្ធិនៅតាមកន្លែងនីមួយៗ ដើម្បីឲ្យកុមារទាំងអស់មានអំណរសប្បាយ។

# THE LOCAL CHURCH PAYS ATTENTION TO YOUNG SCOUTS

Preah Sihanoukville: "My Success", the theme of a camp for young scouts in the Diocese of Phnom Penh. The Pastoral Office for Youth and Children of the Diocese ran the seminar three days from 29 September to 1 October 2017. The camp was held at the parish of St. Michael in the city with some 200 children attending.

They also organized a Mass to conclude the camp with Fr. Un Son as the main celebrant. In his homily the priest instructed all leaders telling them to try hard to practice their faith rather than knowing more theory. "May all of us be good at doing things rather than just speaking. Without putting what we have heard into practice, what we have heard would have been fruitless. Don't forget everything that other people do for you but remember to do everything that God does to you for everyone. All the leaders have to be mindful of the children under the programme for the young scouts," Fr. Un Son continued.

Mr. Sorn Sareoun, a coordinator of the programme said: "This is the time when all the leaders receive more education on new topics and put them into practice at their parish. This has also continued helping the young scouts, especially children who have been less cared for and children who are free on Saturdays and Sundays."

The coordinator thanked the leaders for dedicating their time to help the young scouts in the entire diocese through teaching and instruction. The leaders from nine pastoral sectors of the diocese also thanked and said that during the three days of the camp, they had learnt a lot especially in giving instructions to scouts in each place so that the children can be joyful.

Moreover, they have exchanged personal experiences with one another in what they had and received for educating and handling the young scouts. The leaders are determined to put it into practice what they received from the programme and also try hard to lead the children to do things in the programme to always make progress.

The leaders also thanked the Pastoral Office for youth and Children of the diocese of Phnom Penh for making efforts to plan new lessons and topics for them.



តំណាងគ្រីស្តបរិស័ទជុំគីរី សួរសុខទុក្ខអ្នកក្រីក្រ។ រូបថត ប៊ុន ធឿន

# ព្រះសហគមន៍សន្តយូសែបជុំគីរី ចុះសួរសុខទុក្ខអ្នកក្រីក្រ

លោកបូជាចារ្យ តាវ៉ូឡា យ៉ាំងលូកា ទទួលខុសត្រូវនៅព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពកំពត បានដឹកនាំក្រុមយុវជនមួយចំនួន និងគណៈកម្មការរបស់ព្រះសហគមន៍សន្តយូសែបជុំគីរី ចុះសួរសុខទុក្ខគ្រួសារក្រីក្រមួយគ្រួសារ ក្នុងភូមិកណ្តាល ឃុំជម្ពូវ័ន្ត ស្រុកជុំគីរី ខេត្តកំពត។ ដែលការចុះសួរសុខទុក្ខនេះ បានប្រព្រឹត្តទៅនាវេលាព្រឹកថ្ងៃទី១៣ កញ្ញា ២០១៧នេះ។

បើតាមប្រសាសន៍លោកបូជាចារ្យ តាវ៉ូឡា យ៉ាំងលូកា បានឲ្យដឹងថា ព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពកំពតទាំងមូល មានការចុះទៅសួរសុខទុកបងប្អូនក្រីក្រនៅតាមភូមិជាប្រចាំ និងរៀងរាល់ខែ។ លោកបូជាចារ្យរូបនេះបានបន្តថា គោលដៅសំខាន់នៃការចុះសួរសុខទុក្ខនេះគឺ ចង់ឲ្យប្រជាជនដឹងថាព្រះ-សហគមន៍កាតូលិកយើងតែងតែយកចិត្តទុកដាក់ចំពោះបងប្អូនទាំងអស់ ដែលកំពង់តែជួបការលំបាកក្នុងជីវិត ដោយជួយលើកទឹកចិត្ត និងព្យាយាមជួយរកដំណោះស្រាយ ព្រមជាមួយការឧបត្ថម្ភនូវសម្ភារៈខ្លះៗ ទៅតាមលទ្ធភាពរបស់ព្រះសហគមន៍យើង។ មិនត្រឹមតែប៉ុណ្ណោះ ព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពកំពតទាំងមូល តែងតែមានការជួបជុំពិភាក្សាគ្នា លើកជាគម្រោងការដើម្បីចុះទៅដល់មូលដ្ឋានរបស់ពួកគាត់ផ្ទាល់ និងជួយចូលរួមជួយសម្រួលនូវការលំបាកខ្លះដល់ពួកគាត់ឲ្យបានទាន់ពេលវេលា ហើយសកម្មភាពទាំងនេះគឺជាការប្រកាសដំណឹងល្អទៅមនុស្សទូទៅដែលគេមិនទាន់ស្គាល់ព្រះជាម្ចាស់ផងដែរ។

លោកបូជាចារ្យ លូកា ដដែលបានបញ្ជាក់ថា ព្រះសហគមន៍ក្នុងមណ្ឌលសកម្មភាពកំពតយើង តែងតែធ្វើកម្មវិធីមនុស្សធម៌ជាច្រើនដូចជា ចុះទៅសួរសុខទុក្ខប្រជាជនក្នុងភូមិ ជួយសង់ផ្ទះ ជួសជុលសាលារៀន ធ្វើផ្លូវ ធ្វើស្ពាន ធ្វើអណ្តូងទឹក និងបង្កើតសាលារៀនជាច្រើនកន្លែង មិនជួយឧបត្ថម្ភកូនអ្នកក្រីក្រឲ្យទទួលបានការសិក្សាជាច្រើននាក់ ចាប់ពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សា។

ដោយ ឆាក លាំង

# Local Church members comfort the sick and help the poor

Fr. Gianluca Tavola, the priest in charge of the pastoral sector in Kampot headed members of the youth group and of the parish pastoral committee of the local Church in Chumkiri to visit one poor family in Kandal village, ChompouVoan commune in Kampot province's Chumkiri district.The activities of visiting the village took place on 13 September 2017.

According to Fr. Gianluca Tavola, the parish Churches in the whole Kampot have always conducted visitations of poor families on a regular basis and monthly. The youth group was divided into two groups in order to go down the two villages in the district. The first group went and visited the poor families in Traing Skun village, and another, who was headed up by the priest, visited Kandal village. The priest went on to say that the important target of the visitations was to get local people know that the Church: "We always care for those who are experiencing difficulties, encouraging and trying to help them find a solution. The Church even brought along some of the household materials for them to the best of its ability." Not only does the pastoral sector as a whole always gather for discussion and propose a project to visit their bases directly, the Church help share in their difficulties in a timely manner as well. The activities were the proclamation of the Good News of the Gospel to a general people that have yet to know God.

Fr. GianlucaTavola emphasised: "Our pastoral sector in Kampot has always initiated a humanitarian programme on the visitation of the poor, the building of houses, repairs of schools, roads, bridges, the erecting of pumping wells and the establishment of many schools. This extended a helping hand to many poor people receiving studies ranging from preschool classes to higher education."

It should be pointed out that the pastoral sector located at SovannSokor village, Kampong Bray commune in Kampot city's Kampong Kandal district. The sector has five Churches of Sts. Augustine, Joseph, Peter, Paul in Koh Sla and Michael in Kep Don Bosco with Fr. Gianluca Tavola, the priest in charge, together with two assistant priests.

# បុណ្យភ្ជុំយើងអធិដ្ឋានសម្រាប់មរណបុគ្គល


លោកបូជាចារ្យគោរព ឈើឆ្កាងនិងបុព្វការីដែលស្លាប់។ រូបថត សុវណ្ណភូមិ

ព្រះសហគមន៍កំពត-កែបប្រារព្ធពិធីបុណ្យរំលឹកដល់មរណបុគ្គល ក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ នៅព្រះវិហារកាតូលិកដ៏ចំណាស់មួយក្នុងរមណីដ្ឋានឧទ្យានជាតិព្រះមុនីវង្សភ្នំបូកគោ ដែលមានគ្រីស្តបរិស័ទប្រមាណជា២០០នាក់ចូលរួមកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៧។

ព្រះសហគមន៍កាតូលិកកម្ពុជា បានទទួលការអនុញ្ញាតពីសន្តអសនៈ ក្នុងការប្រារព្ធពិធីបុណ្យគោរពមរណបុគ្គលដែលត្រូវនឹងថ្ងៃទី១ វិច្ឆិកាតាមប្រតិទិនព្រះសហគមន៍កាតូលិកសកល មកប្រារព្ធនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ ដែលជាបុណ្យប្រពៃណីជាតិខ្មែរ រួមជាមួយប្រជាជនកម្ពុជាទាំងអស់។

លោកបូជាចារ្យ តាវ៉ូឡា ចនលូកា ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកក្នុងមណ្ឌលសកម្មភាពកំពត-កែប បានថ្លែងក្នុងធម្មទេសនាថា សម្រាប់ពិធីបុណ្យភ្ជុំ ជាថ្ងៃដែលយើងគិតដល់មរណបុគ្គល យើងត្រូវតែត្រៀមខ្លួនជានិច្ច ព្រោះយើងមិនដឹងថាពេលណាព្រះជាម្ចាស់នឹងត្រាស់ហៅយើងទៅនោះទេ តែយើងត្រូវថែរក្សាពន្លឺនៅក្នុងសេចក្តីស្រឡាញ់ជានិច្ច។

លោកបូជាចារ្យបន្ថែមទៀតថា បងប្អូនយើងដែលបានទទួលមរណភាព យើងដឹងថាបច្ចុប្បន្នរបស់ពួកគាត់មានអំណរសប្បាយណាស់ ព្រោះនៅស្ថានបរមសុខប្រៀបដូចជាក្នុងពិធីជប់លៀងយ៉ាងសប្បាយមួយ ដូច្នេះអ្វីដែលយើងសង្ឃឹមសម្រាប់មរណបុគ្គល គឺបានទទួលអំណរសប្បាយដែលមកពីព្រះជាម្ចាស់។ យើងត្រូវទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គទទួលបងប្អូនយើងដែលបានចែកស្ថានទៅ បានចូលនៅក្នុងព្រះរាជ្យរបស់ព្រះអង្គ។

ចុងក្រោយលោកបញ្ជាក់ថា យើងមានសំណាងដែលបានមកធ្វើបុណ្យនៅព្រះវិហារកាតូលិកលើភ្នំបូកគោនេះ ព្រោះថាមួយរយឆ្នាំមុនក៏មានបងប្អូនយើងមកធ្វើបុណ្យនៅទីនេះដែរ។ ថ្ងៃនេះ ពេលបងប្អូនអធិដ្ឋានសម្រាប់ជីដូនជីតា សូមសម្លឹងមើលរូបព្រះយេស៊ូដែលបង្ហាញព្រះហឫទ័យមេត្តាករុណា នឹងថ្វាយពួកគាត់ទៅក្នុងព្រះហឫទ័យមេត្តាករុណា និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ សូមព្រះជាម្ចាស់ទទួលពាក្យអធិដ្ឋានរបស់យើង ទទួលបំណងប្រាថ្នារបស់យើង ដើម្បីជាប្រយោជន៍ដល់ជីដូនជីតារបស់យើង។

## "Our Pchum Ben Festival for the Departed"

The pastoral sector in Kampot-Kep held a ceremony in memory of the departed during the traditional Khmer Pchum Ben festival at the old Cathedral site in the resort of the Bokor Mountain. Some 200 Catholics attended the ceremony on 19 September 2017.

The Catholic Church in Cambodia was given permission by the Holy See to celebrate the event on the occasion of the Pchum Ben festival for the departed in the traditional Khmer style. The event falls on 1 September 2017 every year, which coincides with the Catholic Church calendar worldwide.

In his homily, Fr. Tavola Gianluca, the priest in charge of the sector said: "This festival is the day when we remember the departed. We have to be always prepared because we do not know when God will call us to Him. So we have to be vigilant always and keep the light of love burning."

"Our brothers and sisters who had passed away make us know that at present they are very joyful because heaven is likened to a happily party. So, we hope the departed are enjoying the joy from God. We have to pray and ask God that He receives our brothers and sisters who left the world for His Kingdom," the priest continued.

The parish priest also emphasised: "We are lucky to celebrate the feast at the Cathedral because last year our brothers and sisters came to perform the ritual here. Today when you pray for your ancestors, please take a look at the image of Jesus showing His mercy and love of God. May God receive our prayers, our wishes for the good of our departed ancestors."

After Holy Mass concluded, the priest told the worshippers to take all the offerings and collections to the Cathedral and offer them to God. The faithful then took the offerings of food for a fellowship meal together in a pleasant atmosphere.



ក្រុមអេម៉ាណូអែល កន្លងមក។ រូបថត សុវណ្ណភូមិ

# ក្រុមអេម៉ាណូអែលរិះគិតអំពីទំនាក់ទំនងជាមួយព្រះជាម្ចាស់

យុវជន២៥នាក់ បានមកទេវវិទ្យាល័យកាតូលិកកម្ពុជា នៅទួលគោក រាជធានីភ្នំពេញចំនួន២៤ម៉ោង ដើម្បីរិះគិតអំពីជីវិតនៃការត្រាស់ហៅដោយដឹកនាំដោយលោកបូជាចារ្យ អ៊ុន សុន ក្រោមប្រធានបទ "ទំនាក់ទំនងខ្ញុំជាមួយព្រះជាម្ចាស់" ត្រូវបានចាប់ផ្តើមពីរសៀលថ្ងៃទី២១រហូតដល់រសៀលថ្ងៃទី២២ តុលា ២០១៦នេះ ។

តាមប្រសាសន៍របស់លោកអ៊ុន សុន ជាបូជាចារ្យដឹកនាំក្រុមនេះបានឲ្យដឹងថា៖ ការរិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់គឺជាសំណួរដ៏សំខាន់ដើម្បីពិនិត្យមើលទំនាក់ទំនងជាមួយព្រះជាម្ចាស់។ លោក បន្តថា៖ លើកទីប្រាំមួយក្នុងឆ្នាំ២០១៧នេះយើងធ្វើនៅទេវវិទ្យាល័យ គឺដើម្បីជួយដល់យុវជនទាំងនេះធ្វើការផ្សារភ្ជាប់ជាមួយទេវវិទ្យាល័យ ដោយបានឃើញជាក់ស្តែងអំពីការអប់រំ និងជីវិតរស់នៅក្នុងទេវវិទ្យាល័យ។

យុវជន ខ្វេត រ៉ាណេត មកពីព្រះសហគមន៍ប៊ូស្រា និងស្នាក់នៅក្នុងមណ្ឌលសន្ត មីកាអែលនៅបឹងទំពន់ បានយល់ឃើញថា៖ ទំនាក់ទំនងខ្ញុំជាមួយព្រះជាម្ចាស់ ពិតជាមានសារសំខាន់ណាស់សម្រាប់ខ្ញុំ ព្រោះថាគ្រីស្តបរិស័ទត្រូវមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងយល់ថាជីវិតរបស់យើងមានព្រះយេស៊ូណែនាំឲ្យដើរទៅមុខ ដែលធ្វើឲ្យមានភាពស្និទ្ធស្នាល និងស្គាល់ពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់កាន់តែខ្លាំងឡើងៗ តាមរយៈព្រះសហគមន៍។

ក្រុមអេម៉ាណូអែលនៅភូមិភាគភ្នំពេញ តែងតែមានការជួបជុំគ្នា៦ដងក្នុងមួយឆ្នាំ ក្នុងនោះផងដែរក៏មានការជួបជុំជាលក្ខណៈអន្តរភូមិភាគចំនួនពីរដង គឺក្នុងទិវានៃការត្រាស់ហៅក្នុងខែឧសភា និងបោះជំរំនៃការត្រាស់ហៅក្នុងខែកញ្ញា។ ក្រុមនេះបានកកើតមានឡើងតាំងពីឆ្នាំ២០០០មកម្ល៉េះ ហើយក្រុមនេះបានជួយដល់យុវជនជាច្រើនឲ្យយល់ពីជីវិតនៃការត្រាស់ហៅជាបូជាចារ្យ។ ជាក់ស្តែងមានបូជាចារ្យ៤រូបហើយដែលជាផលផ្លែចេញមកពីក្រុមនេះ។

ដោយ ដាលីស

# Emmanuel Group Reflects on Relationship with God

A gathering of twenty five youth took place at the Major Catholic Seminary of St. Jean Marie Vianney in Phnom Penh's Toul Kork district for reflection about a vocational life. The gathering was headed by Fr. Un Son. The theme of the meeting was "My relationship with God" starting from the afternoon of 21st October 2017 to 22nd October 2017.

According to Fr. Un Son, the reflection about the calling of God was an important question to be examined on a relationship with God. "This is the sixth time in this year 2017 that we had the gathering at the Seminary in order to help these youth stay connected with the Seminary seeing formation and life in the institution with their own eyes."

In the 24 hours' time, Fr. Un Son saw that the youth had focused their attention in participating at and being happy with the reflection on the faith and the choice of their own life. In the interval, two seminarians also provided witness about a vocational life and living in the Seminary.

Youth Kwet Raneth from the Church in Bousraa and stays at the St. Michael's center in Boeung Tompun held that "These few years, the Emmanuel group has helped a lot with reflection about a priestly life and receiving different experiences making me think more of 'What does God want to call me to do in the future?'" The youth emphasised: "My relationship with God is of very importance for me because Catholics have to have a relationship with God and with understanding that our life has Jesus leading a path toward,which makes it effective and know the love of God more and more through the Church."

The Emmanuel group in the Diocese of Phnom Penh always held such a gathering six times a year with the inter-diocesan meeting two times on the vocational day of May and at the camp in September. The group was established in 2000 and it has gathered a lot of the youth enabling them to understand about a vocational life as a priest. It was clearly evident that there were four local Cambodian priests bearing the fruit ascribed to the group.

# ព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូចប្រារព្ធខួប២៥ឆ្នាំ

គ្រីស្តបរិស័ទ ប្រមាណជាង ១០០០នាក់ មកពីព្រះសហគមន៍នានា ទូទាំងប្រទេសកម្ពុជា ជាពិសេសគ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិកសន្តយ៉ូសែបផ្សារតូច រាជធានីភ្នំពេញ បានជួបជុំគ្នា ក្នុងពិធីបុណ្យអភិបូជាយ៉ាង ឱឡារិក ដើម្បីអរព្រះគុណ និងលើកតម្កើងព្រះជាម្ចាស់ សម្រាប់ខួប២៥ឆ្នាំនៃការកើតឡើងវិញ របស់ព្រះសហគមន៍នេះ។ ពិធីនេះប្រារព្ធខួបធ្វើឡើងនៅទីតាំងព្រះសហគមន៍សន្តយូសែបផ្ទាល់ កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៧កន្លងទៅនេះ ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់លោកអភិបាលព្រះសហគមន៍កាតូលិកទាំង៣ភូមិភាគ។

លោក រឿង ផ័ត្រសិរី ជាបូជាចារ្យទទួលខុសត្រូវព្រះវិហារសន្តយ៉ូសែបផ្សារតូច និងមណ្ឌលសកម្មភាពភ្នំពេញខាងជើងនៃភូមិភាគភ្នំពេញ មានប្រសាសន៍ថា ពិធីនេះឡើងគឺជួយរំឭកគ្រីស្តបរិស័ទឲ្យនឹកឃើញព្រះសហគមន៍របស់ខ្លួនដែលបានកើតឡើងវិញ ដោយចេះចែករំលែកសកម្មភាពជាមួយគ្នា និងរួមចិត្តគំនិតគ្នាជាធ្លុងតែមួយ ដោយអរព្រះគុណព្រះជាម្ចាស់ ដែលជួយក្នុង បង្កើតព្រះវិហារសន្តយ៉ូសែបនៃព្រះសហគមន៍ផ្សារតូចនៅភ្នំពេញនេះ។ លោកបូជាចារ្យ រឿង ផ័ត្រសិរី មានប្រសាសន៍ថា "បើយោងតាមឯកសារ យើងបានទទួលកម្មសិទ្ធិដី និងអាគារនៅទីនេះឡើងវិញ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩២ គឺមានន័យថា ក្រោយពេលព្រះសហគមន៍ ត្រូវបានរដ្ឋអំណាចនៅសម័យនោះ ផ្តល់សិទ្ធិសេរីភាពក្នុងការគោរពបូជាតាមជំនឿរបស់ខ្លួនឡើងវិញ"។

ព្រះសហគមន៍កាតូលិកនៅកម្ពុជាក៏ដូចជាប្រទេសជាតិទាំងមូលត្រូវបានបំផ្លាញដោយសារសង្គ្រាមស៊ីវិលក្នុងរបបប្រល័យពូជសាសន៍។ ក្រោយពីរបបខ្មៅងងឹត បានបញ្ចប់ទៅគ្រីស្តបរិស័ទដែលរស់រានមានជីវិតបានខិតខំប្រមូលគ្នាផ្គុំគ្នាបង្កើតព្រះសហគមន៍ឡើងវិញ។

តាមប្រវត្តិមុនសង្គ្រាមអាគារព្រះវិហារនេះ គឺជាអតីតអនុទេវវិទ្យាល័យអប់រំយុវជន ដែលឈ្វេងរកយល់អំពីជីវិតជាអ្នកបួស មុនពួកគេចូលទៅទេវវិទ្យាល័យ ក្រោយសង្គ្រាមអាគារទាំងនេះត្រូវបានរដ្ឋាភិបាលប្រើប្រាស់ជាកន្លែងស្នាក់នៅរបស់សិស្សសាលាពេទ្យទាហាន។

ក្រោយទទួលបានការអនុញ្ញាត្តិ ពីរដ្ឋមកវិញ ព្រះវិហារនេះជាសេនាធិការដ្ឋាន នៃព្រះសហគមន៍កាតូលិកនៅកម្ពុជា។ ក្នុងធម្មទេសនា លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ស្មិតអឺស្លែរក៏បាន រំលឹកគ្រីស្តបរិស័ទអំពីសកម្មភាពជាច្រើនរបស់ព្រសហគន៍សន្តយ៉ូសែបផ្សារតូចដោយបានបង្កើតដូចជាក្រុមយុវជន មណ្ឌលសុខភាព ក្រុមចំរៀង និងក្រុមគ្រូអប់រំជំនឿជាដើម។ លោកបន្តថា ក្នុងថ្ងៃនេះខ្ញុំសូមអរគុណយ៉ាងខ្លាំងចំពោះវត្តមានលោកបូជាចារ្យមួយចំនួនដែលបានធ្វើសកម្មភាពជាច្រើនជួយឲ្យព្រះសហគមន៍នេះមានជីវិតយ៉ាងរស់រវើក ក្រោយរបបប្រល័យពូជសាសប៉ុលពត រហូតមកដល់បច្ចុប្បន្ននេះ។ ជាពិសេសវត្តមានលោក វីរៈធ័យ ដែលបានបម្រើព្រះសហគមន៍ស្ទើរទាំងអស់ក្នុងប្រទេសកម្ពុជា។



លោកអភិបាលអូលីវីយេ ប្រសិ

លោកអភិបាលអូលីវីយេបានបន្តទៀតថា នៅពេលនេះយើងបានជួបជុំគ្នាកោតសរសើរ លើកតម្កើងព្រះជាម្ចាស់យ៉ាងឱឡារិក ដែលទ្រង់បានប្រទានគ្រប់សកម្មភាពរបស់ព្រះសហគមន៍សន្តយូសែបផ្សាតូច រយៈពេល២៥ឆ្នាំកន្លងមកនេះ ដើម្បីប្រកាសដំណឹងល្អទៅមនុស្សទាំងអស់។ សូមជុំរៀបថា ព្រះសហគមន៍សន្តយូសែបផ្សារតូច មានអាសយដ្ឋានផ្ទះលេខ ១៧៨៨B ផ្លូវជាតិលេខ៥ សង្កាត់ទួលសង្កែរ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ព្រះសហគមន៍មានសកម្មភាពមកដល់ថ្ងៃ

# Twenty Fifth Anniversary of the Rebirth St. Joseph's Church


ទិ្ធពរលើរូបសំណាក សន្តយ៉ូសែប រូបថត សម្បត្តិ

នេះដោយមានវត្តមានលោកបូជាចារ្យចំនួន៥អង្គគឺ អតិត អភិបាល អេមីល ដេតម្ប លោកបូជាចារ្យ វីរៈជ័យ លោកបូជាចារ្យ បប់ ពិសេ លោកបូជាចារ្យ ប្រ៊ូណូ កូស៍ និងលោកបូជាចារ្យ រឿង ឆ័ត្រសិរីនាពេលបច្ចុប្បន្ននេះ។

ដោយ ឆាក លាំង

Approximately one thousand Catholics from the three dioceses in Cambodia, mostly from Phsar Toich in Pnom Penh congregated at the parish of St. Joseph to celebrate the 25th anniversary of its rebirth. The anniversary was meant to thank and glorify God for the rebirth after the civil war in Cambodia. The ceremony took place on 7th October 2017. Bishop Oliver Schmittaeusler of the Apostolic Vicariate of Phnom Penh celebrated Holy Mass, which was concelebrated by the two Apostolic Prefects, Msgr. Enrique Figaredo of Battambong and Msgr. Antonysamy of Kampong Cham Prefectures, together with many other priests.

Fr. Reoung Chhatsirey, the priest in charge of the Church in Phsar Toich and the pastoral sector in northern Phnom Penh said that the ceremony reminded the Catholics present about the Churches that were re-established. The rebirth made them share in activities together and they even were of one heart to thank God for assisting in creating the church of St. Joseph.

The priest continued by saying the church had renewed life after the civil war during the Pol Pot regime. Regard to Church history, Fr. Chhatsirey said: “We received the title of a piece of land and the building of the church again on 7th October 1992. This meant that the Church was given the freedom by the regime in order to practice their faith again.”

The Catholic Church in Cambodia was destroyed by the civil war during the Pol Pot regime. Many of the churches, schools, monasteries, shelters for the sick and other church-owned buildings were destroyed almost completely. Many priests and Cambodian Catholics were tortured and killed. After that dark regime ended, surviving Catholics had tried hard to gather again to rebuild the Churches. According to history, before the outbreak of the war, a building that used to be the minor Catholic Seminary was running well for educating the youth who had learnt to understand the religious life before having entering the Major Catholic Seminary but after the civil war this building was used by the state as a medical facility. Having given permission from the state, the church of St Joseph is the main headquarters of the Catholic Church in Cambodia. Many of pastoral activities have been initiated from here in terms of reflections, projects and plans for the local Church.

In his homily, Bishop Olivier reminded the Catholics gathered about the many activities of the Church of St. Joseph being initiated including a health center, a church choir, Catechists and youth formation and so on. “Today I am grateful for the presence of some priests who had carried out activities to help the Church stay alive after the Pol Pot regime until today. In particular, Fr. Werachai Sri Pramong who had served the Church to the best of his ability. Today, we congregate to praise and glorify God solemnly for He has guided every activity in the Church of St. Joseph for the last 25 years in order to proclaim the Good News of the Gospel to all people. Dear brothers and sisters, today we unite with St. Joseph to thank God for the peace in the Church throughout Cambodia,”

Bishop Olivier also said: “Today we have as many as nine pastoral sectors so we Catholics have to unite with St. Joseph’s church to spread the news of the Gospel to more and more people. At present and in the future, there will be not only louder voices singing songs and praying but will continue with many other activities such as works of Charity and Mercy in the whole of Phnom Penh.”

Please be informed that St. Joseph’s Church is located at # 1788B, St. 5, Toul Sangke district, Khan Russey Keo, in Phnom Penh. Church’s activities that have been carried out are due to the presence of five priests – the late Bishop Emile Destombes, Frs.Werachai, Bob Piché, Bruno Cosme and Chhatsirey.

# ក្រុមគ្រួសារបងស្រី ព្រះមាលាត្រូវរំសាយ



ក្រុមបងស្រីព្រះមាលាកន្លងមក រូបថត សុវណ្ណភូមិ

ក្រុមបព្វជិតាបងស្រីព្រះមាលា បានបង្កើតឡើងក្នុងឆ្នាំ១៨៣២ នៅក្នុងប្រទេសបារាំងត្រូវបានរំលាយ ក្នុងឆ្នាំ២០១៧នេះ។ បងស្រីអាន ម៉ារីហ្គាលីស ជាអ្នកទទួលខុស ត្រូវក្រុមគ្រួសារបងស្រីព្រះមាលានៅប្រទេសកម្ពុជាមានប្រសាសន៍ថា "ដោយសារតែក្រុមយើងមានតែមនុស្សចាស់ៗ នៅបារាំងអត់មានយុវនារីចង់បួសក្នុងក្រុមយើង ដូច្នេះក្រសួងបព្វជិត-ជិតានៅទីក្រុងរ៉ូមស្នើសុំឲ្យយើងបញ្ចប់សកម្មភាព"។ បងស្រី ឲ្យដឹងថា សព្វថ្ងៃនេះ នៅប្រទេសបារាំងមានសុទ្ធតែដូនជីចាស់ៗ "ហើយអ្នកដែលក្មេងជាងគេគឺខ្ញុំនិងបងស្រីម្នាក់ទៀត។ ខ្ញុំមានអាយុ៦៩ឆ្នាំហើយ ក្រៅពីនោះគេចាស់ជាងខ្ញុំច្រើនណាស់"។

ក្រុមគ្រួសារបងស្រីព្រះមាលា បានបំពេញបេសកកម្មនៅក្នុងទ្វីបអាស៊ី និងអាហ្វ្រិក។ ក្រុមគ្រួសារនេះ មានវត្តមាននៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩៣ និងធ្លាប់មានបេសកកម្មនៅក្នុងជំរំជនភៀសខ្លួននៅព្រំដែន ខ្មែរ ថៃជាច្រើនឆ្នាំ គឺបងស្រី ហ្ស៊ីលប៊ែត ម៉ាសុងជាបេសកជនដែលមកបំពេញកិច្ចការងារមនុស្សធម៌។

បងស្រីអាន ម៉ារី បានរៀបបន្តថា បេសកកម្មរបស់ក្រុមគ្រួសារបងស្រីព្រះមាលានៅតាមបណ្ដាប្រទេសនីមួយៗគឺធ្វើតាមជំនាញ និងសមត្ថភាពរបស់ខ្លួនដើម្បីបម្រើព្រះជាម្ចាស់ និងព្រះសហគមន៍ក្នុងតំបន់។ កិច្ចការទាំងនោះរួមមាន អប់រំ-ជំនឿ ធ្វើកិច្ចការងារក្នុងព្រះសហគមន៍ ធ្វើកិច្ចការមនុស្សធម៌នៅខាងក្រៅ ជួយដល់គ្រួសារក្រីក្រ និងកុមារឲ្យទទួលបានការសិក្សារៀនសូត្រជាដើម។

នៅក្នុងប្រទេសកម្ពុជាក្រុមបងស្រីព្រះមាលា មានសមាជិកចំនួន៣នាក់ គឺបងស្រីអានម៉ារី ហ្គាលីស, បងស្រីហ្ស៊ីលបែត ម៉ាសុង ដែលជាជនជាតិបារាំង និងបងស្រីឃឹម សុខា ជាជនជាតិខ្មែរដែលក្មេងខ្ចី។ ក្នុងប្រទេសកម្ពុជាក្រុមគ្រួសារបងស្រីបានបង្កើតអង្គការពន្លកថ្មី គឺជួយឧបត្ថម្ភដល់គ្រួសាក្រីក្រដើម្បីឲ្យកុមារទទួលបានការសិក្សានៅតាមសាលារដ្ឋ ជួយដល់កិច្ចការងាររបស់ព្រះសហគមន៍ក្នុងភូមិភាគភ្នំពេញ ជួយអប់រំជំនឿ និងធ្វើការសហការចងក្រងសៀវភៅអប់រំជំនឿសម្រាប់អ្នកឈ្វេងយល់ជំនឿ។

## Congregation of the Sisters of the Rosary closes

The congregation of the Sisters of the Rosary was established in 1832 in France. Unfortunately the group has now been disbanded this year, 2017. Sr. Anne Marie Gallice, the person in charge of the group in Cambodia said: “Because our group has only old people in France, there were no youth willing to take the veil in our group and so the Mother House in Rome has asked us to discontinue activities here in Cambodia. At present in France almost all the nuns are old and the youngest of them is me who is 69 years old and another nun. There are even nuns much older than me.”

The congregation of the Sisters of the Rosary had carried out pastoral missions in Asia and Africa. The group was set up in Cambodia in 1993 and it used to have missions in the refugee camps on the Cambodia-Thailand border for a number of years with Sr. Zilbel Mason who had performed humanitarian works.

In Cambodia, the congregation of the Sisters of the Rosary comprises three members including Srs. Anne Marie Gallice, Zilbet Mason, a French national and Khem Sokha, the youngest Cambodian national.

In Cambodia, the congregation of the Sisters of the Rosary had established an organization of neophytes in order to assist poor families so that their children will receive studies at state-run schools. The organization is also helping the parishes in the Diocese of Phnom Penn in catechetical programmes and compiling catechetical books for catechumens. The organization even accommodates female youth by helping in their studies who are from high schools and universities.

The nun said that the organization of neophytes is still continuing its mission because the organization has a person in charge along with other staff. The nun added that there is only one person to help the organization with financial contribution. However, accommodating the youth will be suspended from next year, while other works are due to be stopped this year.

# ពលកររួមគ្នាដើម្បីសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារ



សកម្មភាពកម្មករកម្មការិនីបង្ហោះប៉េតប៉ោងនៅភ្នំពេញថ្មី រូបថត សុវណ្ណភូមិ

នៅព្រះវិហារសន្តប៉ូល និងសន្តសិលា នៃមណ្ឌលសកម្មភាពភ្នំពេញថ្មី នៅកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧កន្លងទៅនេះគណៈកម្មការពលករ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំកម្មវិធីមហោស្រពពលករមួយដែលទាក់ទងទៅនិងប្រធានបទ ពលកររួមគ្នាដើម្បីសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារ ។

កម្មវិធីនេះមានការចូលរួមជាកិត្តិយសពីសំណាក់លោកអភិបាលអូលីវីយេ និងលោកបូជាចារ្យមួយចំនួន ដែលជួយនៅក្នុងគណៈកម្មការពលករ និងបងប្អូនកម្មករ កម្មការិនីប្រមាណជាង១០០នាក់ ហើយកម្មវិធីនេះមានគោលបំណងជួបជុំជាមួយបងប្អូនជាកម្មករ កម្មការិនីនៅតាមបណ្ដារោងចក្រមួយចំនួននៅក្នុងរាជធានីភ្នំពេញ ដើម្បីឲ្យពួកគេមានឱកាសកម្សាន្តរួមគ្នាចែករំលែកបទពិសោធន៍នៃជីវិតរស់នៅរបស់ពួកគេម្នាក់ៗ ដែលធ្លាប់បានជួបប្រទះក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

លោកអូលីវីយេ ជ្មីអ៊ីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានមានប្រសាសន៍លើកទឹកចិត្តកម្មករ កម្មការិនី ដែលចូលរួមកម្មវិធីនាថា នេះជាឱកាសមួយសម្រាប់ព្រះសហគមន៍កាតូលិក ដើម្បីបង្ហាញពីការយកចិត្តទុកដាក់សម្រាប់កម្មករ ដែលសព្វថ្ងៃនេះ នៅប្រទេសកម្ពុជាមានកម្មករប្រមាណជា៨០ម៉ឺននាក់។ បើទោះបីព្រះសហគមន៍កាតូលិកមិនមានសកម្មភាពច្រើនក្ដី ប៉ុន្តែព្រះសហគមន៍បានរៀបចំឲ្យមានមណ្ឌលមួយ សម្រាប់ទទួល និងជួយដល់កម្មករ កម្មការិនីខ្លះៗ ដែលធ្វើការតាមរោងចក្រ។ យើងមានក្រុមចលនាយុវកម្មករគ្រីស្តបរិស័ទ ដើម្បីប្រមូលកម្មករ កម្មការិនី ដើម្បីរិះគិតអំពីតម្លៃនៃជីវិត ដើម្បីរិះគិតអំពីអត្ថន័យនៃការងារ និងរិះគិតអំពីជីវិតនៃការរស់នៅជាក្រុមជាដើម។

ដោយ ឡុង សម្ផស្ស

# WORKERS UNITE FOR THEIR RIGHTS

The Pastoral Committee on Labor in the Diocese of Phnom Penh organized a gathering with the theme "Workers unite for your Rights". The gathering took place on 8 October 2017 at the parish of Sts. Peter and Paul in Phnom Penh Thmei. Bishop Olivier Schmittaeusler of the Apostolic Vicariate of Phnom Penh chaired the meeting, together with certain priests along with approximately 100 workers from Phnom Penh-based factories. The gathering provided them with the opportunity to have entertainments and share their personal experiences in life from one another.

Bishop Olivier encouraged the workers present, saying that this is a chance for the Catholic Church to show its interest in them. The Cambodian workers of today were estimated at about 800,000. In spite of the Church not having many such activities, it had prepared a center to receive and help some of the workers. "We have the youth movement of Catholics to gather the garment workers to reflect on their life value in order to think about the meaning of life in groups and so on."

Chom Sothea aged 33, an ISI factory worker in Phnom Penh who attended the gathering, showed his interest by saying: "The gathering of the garment workers was intended to encourage all of them to struggle and unite with a clear understanding about labour laws and advocacy for their rights as stipulated by the labour laws of our Kingdom of Cambodia."

It should be pointed out that the Pastoral Committee on Labour was formed by the local Church in Phnom Penh with the purpose of helping garment factory workers in terms of their working rights and advocacy so that their rights will be respected.

The office of the committee is located at Rung Roeung Stree, Village 1 Toul Pongro, Chom Chao district 3 in Khan Po Senchey in the vicinity of the blue-roofed factory.

# ទេវវិទ្យាល័យកម្ពុជា បានប្រកាសទទួលបេក្ខជន ប្រាក់ ប៊ុនហុង និងវិន កាន់ ជានិស្សិតផ្លូវការ



លោកអភិបាល លោកបូជាចារ្យ និងនិស្សិតទេវវិទ្យាល័យ រូបថត លីហៀង

ទេវវិទ្យាល័យព្រះសហគមន៍កាតូលិកកម្ពុជា នៅក្រុងភ្នំពេញ បានប្រកាសទទួល លោកប្រាក់ ប៊ុនហុង និងលោក វិន កាន់ ជានិស្សិតផ្លូវការនៅក្នុងថ្ងៃបើកឆ្នាំសិក្សាថ្មីនេះ ដើម្បីរៀន និងរិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងជីវិតជាបូជាចារ្យ។

កម្មវិធីនេះធ្វើឡើង ក្រោមអធិបតីភាពរបស់លោកអភិបាល ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតអឺស្លែរ លោកអន់តូនី ស៊ូសៃរាជ្យ អភិបាលនៃព្រះសហគមន៍ភូមិភាគកំពង់ចាម និងលោកបូជាចារ្យ ជានាយកទេវវិទ្យាល័យដោយមានអ្នកចូលរួមជាច្រើននាក់ កាលពីថ្ងៃទី១១ តុលា ២០១៧នេះ។

លោកអូលីវីយេ និងលោកអន់តូនី បានប្រកាសសួរបេក្ខជនក្នុងការស្ម័គ្រចិត្ត ដើម្បីថ្វាយជីវិតបម្រើព្រះសហគមន៍ និងប្រជា-រាស្ត្ររបស់ព្រះជាម្ចាស់ ព្រោះតែស្រឡាញ់ព្រះយេស៊ូ ដោយបន្តទទួលការអប់រំ និងត្រៀមខ្លួនធ្វើជាបូជាចារ្យដើម្បីបម្រើភូមិភាគរៀងៗខ្លួន។

បន្ទាប់ពីបេក្ខជនទាំងពីររូប បានប្រកាសយល់ព្រមស្ម័គ្រចិត្ត តាមការសាកសួរខាងលើ លោកអភិបាលអូលីវីយេ និងលោកអភិបាលអន់តូនី បានយល់ព្រមទទួលបងប្រុសហុង និងបងប្រុសកាន់ឲ្យទៅជានិស្សិតផ្លូវការតាមប្រពៃណីព្រះសហ-គមន៍កាតូលិក ដោយមានលិខិតស្នាមត្រឹមត្រូវ។

បេក្ខជន វិន កាន់ បានឲ្យដឹងអំពីគោលបំណង និងការតស៊ូដើម្បីទទួលការអប់រំជាបូជាចារ្យព្រោះ ជីវិតជាលោកបូជាចារ្យគឺមានអំណរសប្បាយខ្លាំង មិនថាតាមលោកីយ៍ ឬខាងវិញ្ញាណនោះទេ។ លើសពីនេះទៅទៀត លោកកាន់ ចាប់អារម្មណ៍ខ្លាំងអំពីបូជាចារ្យ ដែលមានតួនាទីនាំសេចក្តីសុខសាន្ត ព្រះពរ និងការសង្គ្រោះរបស់ព្រះយេស៊ូដល់មនុស្សឯទៀតៗ។ បេក្ខជនរូបនេះបន្តថា បំណងជាបូជាចារ្យគឺ រស់នៅជាមួយព្រះយេស៊ូ ត្រូវអធិដ្ឋានស្រឡាញ់កិច្ចការព្រះសហគមន៍ និងបំពេញតួនាទីរបស់ខ្លួនឲ្យបានគ្រប់គ្រាន់ ដែលជាសញ្ញាដែលព្រះជាម្ចាស់កំពុងត្រាស់ហៅយើង។

ព្រះសហគមន៍កាតូលិក នៅកម្ពុជា បានខិតខំជួយយុវជនក្នុងការរិះគិតអំពីការត្រាស់ហៅនេះយ៉ាង ដើម្បីឲ្យហ៊ានសម្រេចចិត្តឆ្លើយតបទៅព្រះជាម្ចាស់តាមជំនឿរបស់ខ្លួន។ ការអធិដ្ឋាននេះបានផ្តល់នូវផលផ្លែដោយមានយុវជនម្នាក់ថ្មី និងនិស្សិតចាស់៨នាក់ទៀតបានស្ម័គចិត្តចូលទេវវិទ្យាល័យដើម្បីរិះគិតអំពីដំណើរជីវិតជាបូជាចារ្យ ក្នុងឆ្នាំ២០១៧- ២០១៨នេះ។

ដោយ ដាលីស

## Brack Bunhong and Vin Kann gain admission to the Catholic Major Seminary

Bishop Olivier Schmittaeusler declared open the new academic year of 2017-2018 for the Catholic Major Seminary of St. Jean Marie Vianney with a Eucharistic celebration. During the Eucharistic Bishop Olivier made a formal announcement and the rite of admission of candidates Brack Bunhong and Vin Kann to the Seminary. They now officially become seminarians. The two candidates were studying at the institution to reflect on the call of God of living a priestly life.

The main celebrant of the Eucharistic was Bishop Oliver and concelebrated by the Apostolic Prefect, Msgr. Antonysamy of Kampong Cham Prefecture, together with Fr. Bob Piché, the rector of the seminary. A good number of people attended the ceremony on 11th October 2017.

Then the two candidates aswered "yes" by saying: "We are willing to follow our commitment." The two main celebrants agreed to rececive the two candidates into the seminary with the appropriate writen notes.

Vin Kann said by showing his intention that by receiving priestly formation for a priestly life with joy it prepares him both earthly and spiritual life. The seminarian even showed his determined interest to the priesthood whose role is to bring peace, blessing, and salvation of Jesus for other people. "The intention of becoming a priest is to live with Jesus, pray, love with focus on the pastral affairs of the Church.

# ពិធីបញ្ចុះបឋមសិលា សាងសង់ព្រះវិហារថ្មី



លោកអភិបាលប្រសិទ្ធិពរលើរណ្តៅគ្រឹះព្រះវិហារ រូបថត អន ហំ

ពិធីបញ្ចុះបឋមសិលា សាងសង់ ព្រះវិហារថ្មីនៅព្រះវិហារសន្ត យ៉ូសែប ជុំគីរី នៃមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកតំបន់កំពត។ ពិធីនេះបានប្រារព្ធឡើងក្រោមអធិបតីភាព របស់លោកអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគ ភ្នំពេញ កាលពីថ្ងៃទី១៥ តុលា ២០១៧កន្លងទៅ ដោយមានវត្តមានលោកបូជាចារ្យ និងគ្រីស្តបរិស័ទ ចូលរួមយ៉ាងច្រើនកុះករ។

ក្នុងធម្មទេសនា លោកអភិបាលបានមានប្រសាសន៍ថា៖ បងប្អូនជាថ្ម ដ៏មានជីវិត បងប្អូនជាកម្លាំង ដើម្បីឲ្យព្រះសហគមន៍យើងបន្តមានជីវិត ក្នុងអំណរសប្បាយរបស់ព្រះជាម្ចាស់។ លោកបន្តថាបន្តិចទៀតយើងប្រារព្ធពិធីបញ្ចុះបឋមសិលា ដោយមានថ្មរឹង ដែលភ្ជាប់ដោយស៊ីម៉ង់ត៍សម្រាប់អាគារ ដែលមេជាងនឹងសាងសង់។ ប៉ុន្តែយើងជាព្រះសហគមន៍ជាថ្មដ៏មានជីវិត និងភ្ជាប់ដោយ ស៊ីម៉ង់ត៍របស់យើងគឺ ដង្ហើមរបស់ព្រះជាម្ចាស់ ដែលជាសេចក្តីស្រឡាញ់បងប្អូនទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យព្រះសហគមន៍មានកម្លាំងដូចក្រុមគ្រីស្តទូត។

លោកអភិបាលបន្តថា នៅទីនេះមិនទាន់មានព្រះវិហារអស់រយៈពេល២៥ឆ្នាំ តែព្រះសហគមន៍ មានកម្លាំង និងជីវិតរស់រវើក។

តាមប្រសាសន៍លោកចនលូកា ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពតំបន់កំពតបានឲ្យដឹងថា ព្រះវិហារថ្មីនេះមានទំហំ ១៤ម៉ែត្រ គុណនិង ២២ម៉ែត្រ ។ លោកថាការសាងសង់អាចនឹងបញ្ចប់រួចរាល់ប្រហែលជាចុងឆ្នាំ២០១៨។

ព្រះសហគមន៍នៅជុំគីរី បានចាប់ផ្តើមឡើងតាំងពីឆ្នាំ១៩៩៣ ដោយគ្រីស្តបរិស័ទដែលបានធ្វើមាតុភូមិនិវត្តន៍មកពីជំរំជនភៀសខ្លួន តាមបណ្តោយព្រំដែនខ្មែរថៃ។

តាមប្រសាសន៍របស់លោកបូជាចារ្យចនលូកា សព្វថ្ងៃនេះព្រះសហគមន៍នេះមានជីវិតរស់រវើក មានសកម្មភាពជួយអ្នកក្រីក្រ មានក្រុមស្ត្រី មានថ្នាក់បង្រៀនភ្លេង មានសាលាមត្តេយ្យដែលមានសិស្សជាច្រើន បានជួយយុវជនជាច្រើនឲ្យបន្តការសិក្សានៅមហាវិទ្យាល័យជាដើម។ លោកបន្តថា សព្វថ្ងៃដោយសារសកម្មភាពមេត្តាករុណាមានបងប្អូនពីរភូមិទៀតបានកំពុង ទទួលការអប់រំជំនឿអំពីព្រះយេស៊ូ។

## Groundbreaking ceremony for New Church

St. Joseph's Church in Chumkiri had a ground breaking ceremony for a new church in the pastoral sector of Kampot. The ceremony took place on 15th October 2017, which was officiated by Bishop Olivier Schmittaeusler of the Apostolic Vicariate of Phnom Penh. A good number of people attended the ceremony which included priests and parishioners.

In his speech, Bishop Olivier said: "Brothers and sisters are the living stone. Brothers and sisters are the strength for our Church to renew life in the joy of God. In a little while, we will break ground for a new construction with solid stones to be mixed with cement. However, we are the Church of Living Stones and we are connected together like cement, namely: the breath of God, who is the love for brothers and sisters receiving from the Holy Spirit, who leads the Church to have powers like the Apostles."

His Excellency, Bishop Olivier said that in this place there have been no churches yet for 25 years ago and yet the Church has the strength and life in a vivid manner. "Please continue building in each place with the priests' help." The Bishop also reminded youth that the priest alone cannot do everything. The youth, please participate and become a special stone in order for the Church to have plenty of pastors and many more Catholic nuns."

According to Fr.Gianluca Tavola, the priest in charge of the pastoral sector, the new church measures 14 meters by 22 meters. The construction was scheduled to be completed in 2018.

The parish in Chumkiri was established in 1993 with Catholics who were deported from the refugee camp along the Thailand/Cambodia border. Having arrived in their homeland, Fr. Gianluca said that all the activities in the Church having such an active life are attributed to the Providence of God. Although the Church is still small in size, there are youth reflecting on priestly vocation. There is one nun from this place – Sr. Srey Socheat belonging to Sisters, lovers of the Cross.

# គ្រីស្តបរិស័ទ៣០នាក់ ទទួលអគ្គសញ្ញាលាបថ្ងាស នៅព្រះវិហារ សន្ត សិលានិងសន្តប៉ូល





បេក្ខជនដែលបានទទួលអគ្គសញ្ញាលាបថ្ងាសពីលោកអភិបាល រូបថត សុវណ្ណភូមិ

បេក្ខជន បេក្ខនារីចំនួន ៣០នាក់មកពីព្រះវិហារសន្ត សិលា និងសន្ត ប៉ូលព្រះវិហារសន្ត សិលា( ពោធិ៍ចិនតុង ) និងព្រះវិហារសន្តយ៉ូសែប( កំពង់ស្ពឺ ) បានទទួល អគ្គសញ្ញាលាបថ្ងាស ដើម្បីផ្តល់កម្លាំងក្នុងការចេញទៅប្រកាសដំណឹងល្អកាលពីថ្ងៃទី២២ ខែតុលា ២០១៧ នៅព្រះវិហារសន្ត សិលានិងសន្តប៉ូល នៃមណ្ឌលសកម្មភាពភ្នំពេញថ្មីដោយមានលោក អូលីវីយេ ដ្មឹត អីស្ល៊េរ ជាអធិបតី និងមានបងប្អូន គ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។

នៅក្នុងធម្មទេសនាលោកអូលីវីយេ បានមានប្រសាសន៍ទៅកាន់បេក្ខជនថា "នេះជាឱកាសមួយដើម្បីយកព្រះគ្រីស្តជាទីពឹង"។ លោកបញ្ជាក់បន្ថែមថាគ្រីស្តបរិស័ទគឺជាបរិស័ទដែលជាប់ជាមួយព្រះគ្រីស្តផ្ទាល់ ប្រសិនបើគ្មានព្រះគ្រីស្តដឹកនាំជីវិតយើងឲ្យមានសេចក្តីស្រឡាញ់និងអំណរសប្បាយនោះយើងមិនខុសពីអង្គការមនុស្សធម៌ឡើយតែយើងខុសគ្នាដោយសារយើងមានព្រះគ្រីស្តជាផ្លូវជាជីវិតនិងជាសេចក្តីពិត។

លើសពីនេះទៅទៀត លោកអូលីវីយេក៏បានផ្តាំផ្ញើរដល់បេក្ខជន និងគ្រីស្តបរិស័ទទាំងអស់ ដោយលើកយកពីរចំនុចនៃសារលិខិតសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក្នុងឱកាសទិវាប្រកាសដំណឹងល្អ៖ ១)ឲ្យយកចិត្តទុកដាក់ធ្វើជាគ្រូគង្វាលដ៏សប្បុរសដោយស្រឡាញ់ ថែទាំគ្នាទៅវិញទៅមក និងចេះលើកទឹកចិត្តគ្នាជាពិសេសដល់បងប្អូនដែលលែងចូលព្រះវិហារ។ ២)ត្រូវធ្វើជាអ្នកសប្បុរសដូចជនសាម៉ារី ដោយណែនាំសេចក្តីស្រឡាញ់ដែលជាថ្នាំព្យាបាលគ្រប់ជំងឺ ដល់បងប្អូនមួយចំនួនដែលមិនមែនជាគ្រីស្តបរិស័ទ និងគ្មានសេចក្តីសង្ឃឹម។

បន្ទាប់ពីធម្មទេសនាលោកអភិបាលបានសួរបញ្ជាក់អំពីជំនឿរបស់បេក្ខជនចំពោះព្រះជាម្ចាស់នៅក្នុងពិធីទទួលអគ្គសញ្ញាលាបថ្ងាស និងប្រកាសធម៌ជឿរួមជាមួយគ្រីស្តបរិស័ទទាំងអស់ រួចទូលអង្វរព្រះជាម្ចាស់រួមជាមួយសន្តបុគ្គលទាំងអស់ដើម្បីសូមព្រះវិញ្ញាណយាងមកគង់សណ្ឋិតជាមួយបេក្ខជនទាំងនោះ ដើម្បីឲ្យពួកគេទទួលបានផលផ្លែនៃព្រះវិញ្ញាណគឺ ១) មានប្រាជ្ញាឈ្លាសវៃ។ ២) ដឹងខុសដឹងត្រូវ។ ៣) ដឹងអំពីសេចក្តីពិត។ ៤) មានយោបល់ល្អ។ ៥) មានសេចក្តីអង់អាច។ ៦) ប្រព្រឹត្តតាមការណែនាំរបស់ព្រះវិញ្ញាណ។ និង៧) ចេះគោរពកោតខ្លាចព្រះបិតា។

បេក្ខនារីឈៀងរចនាជាបុគ្គលិកនៃអង្គការផ្នែកត្រចៀកនៅកម្ពុជា បាននិយាយថា "ថ្ងៃនេះខ្ញុំបានទទួលកម្លាំងដ៏រឹងមាំដើម្បីបន្តដំណើរទៅមុខជាមួយព្រះយេស៊ូដើម្បីបន្តប្រកាសដំណឹងល្អ ដោយមានគម្រោងប្រមូលកុមារនៅតំបន់អង្គស្នួលជាមួយបងស្រីកាមែល ឲ្យស្គាល់ព្រះជាម្ចាស់តាមរយៈអំណរសប្បាយជាមួយយើង"។ រចនាបានស្គាល់ព្រះសហគមន៍នៅឆ្នាំ២០១១ តាមរយៈបព្វជិតាកាតូលិកនៅសាលាពេទ្យដោយចាប់អារម្មណ៍លើភាពជិតស្និទ្ធដែលជាសេចក្តីស្រឡាញ់ប្រកបដោយភាពកក់ក្តៅទើបអាចទទួលអគ្គសញ្ញាជ្រមុជទឹក និងលាបថ្ងាសនៅឆ្នាំ២០១៧នេះ។

តាមឯកសារអប់រំជំនឿនៃព្រះសហគមន៍កាតូលិកបាននិយាយថា៖ អ្នកដែលទទួលអគ្គសញ្ញា លាបថ្ងាស គឺអស់អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយ។ អគ្គសញ្ញានេះ គឺបញ្ជាក់បន្ថែមថា បងប្អូនជាគ្រីស្តបរិស័ទ ពេញលក្ខណៈ ព្រះជាម្ចាស់ត្រាស់ហៅបងប្អូនឲ្យទទួលព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីបញ្ជាក់ជំនឿរបស់ខ្លួន និងចាត់ឲ្យបងប្អូនចេញទៅ ប្រកាស ដំណឹងល្អអំពីជំនឿរបស់ខ្លួន ធ្វើជាសាក្សីនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដល់មនុស្ស ដែលនៅជុំវិញយើង។

ដោយ ដាលីស

# Thirty Candidates Receive Sacrament of Confirmation

Thirty candidates received the sacrament of confirmation at the parish of Sts. Peter and Paul in Phnom Penh which was celebrated by Bishop Olivier Schmittaeusler. The ceremony took place on 22 October 2017, and was attended by many Catholics. The 30 candidates came from the Churches of Sts. Peter and Paul, the Church of St. Peter in Pochentong, and the Church of St. Joseph in Kampong Speu.

The Sacrament of confirmation is a source of strength to go out and proclaim the Good News of the Gospel. In his homily Bishop Olivier said: "This is a opportunity to take Christ as the Helper. Catholics are united to Christ Himself. Without Christ leading our lives to love and joy, we would not have been different from secular charity organizations, but we are different because we have Christ who is the way and the truth."

His Excellency Bishop Olivier also instructed all the candidates and the faithful present by highlighting some points from the letter of the Holy Father, Pope Francis on Vocational day as follows:

"First, it enables us to serve as good pastors with love, to take care of each other and encourage each other, especially our brothers and sisters who no longer go to church. Second, you have to serve as generous people as the Good Samaritan bringing love that is the medicine to treat the disease that afflicts some of non-Catholics and those without hope."

Following the homily, Bishop Oliver asked the candidate questions about their faith in God at the confirmation rite. They then professed the Creed together with the faithful and petitioned God with all Saints in order for the Holy Spirit to come on the candidates. It is hoped that they receive the sevenfold gifts of the Holy Spirit. First, the gift of wisdom, second, the gift of understandingg ,third, the gift of truth, fourth, the gift of counsel, fifth, the gift of strength, sixth the gift of knowledge, and seventh the gift of reverence for the Father.

Candidate Chheang Ratana said: "Today I received firm strength to continue a journey forward with Jesus in order to spread the Good News of the Gospel with a plan to raise money for children in Ang Snoul district with the Carmelite Sisters knowing God through joy in us." Ratana came to know of the Church in 2011 through a Catholic nun at a medical school. She then showed her interest in closeness, which signified a desire to receive the sacrament of baptism and confirmation this year in 2017.

According to The Tradition of the Catholic Church , whoever received the sacrament of confirmation are those who have already been baptized. This Sacrament is a complementary service to Baptism. God called them to become full Catholics so that they received the Holy Spirit to profess their faith. They will be sent to go out and spread the Good News of the Gospel to other people and they even act as the mercy of God for people around us.



# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាខួប២៥ឆ្នាំនៃព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច
# ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៧

បងប្អូនជាទីស្រឡាញ់!

សូមស្វាគមន៍ដល់បងប្អូនទាំងអស់ ដែលមកពីភូមិភាគភ្នំពេញ ភូមិភាគបាត់ដំបង និងកំពង់ចាម ដើម្បីអធិដ្ឋានរួមជាមួយគ្នា។ ពិតមែន ជាឱកាសមួយយ៉ាងល្អ ដើម្បីអរព្រះគុណព្រះជាម្ចាស់ ដើម្បីឲ្យយើងមានកម្លាំងថ្មី ដើម្បីបន្តកសាងព្រះសហគមន៍របស់យើង។ ជាពិសេស យើងសូមស្វាគមន៍ និងអរគុណដល់លោកឪពុក វីរៈជ័យ ដល់លោកឪពុក ប៊ីប់ ដែលបានជួយណែនាំព្រះសហគមន៍នេះបន្តពីលោកអេមីល និងក្រោយមកលោកប៉្រុយណូ និងសព្វថ្ងៃលោកធ័ត្រសីរី។

ថ្ងៃនេះ យើងមិនរំឭកដល់ថ្ងៃដែលយើងកសាងអាគារ គេហៅអនុទេវវិទ្យាល័យនៅក្នុងឆ្នាំ១៩១២។ ថ្ងៃនេះ យើងមិននឹករឭកដល់ពេលវេលាដែលកន្លែងនេះបានបិទទ្វារអស់ហើយនៅក្នុងសម័យប៉ុលពត និងបន្តពីសម័យប៉ុលពតក៏មិនអាចប្រើបានទេ។ ប៉ុន្តែថ្ងៃនេះយើងមានអំណរសប្បាយ ដោយសារថ្ងៃនេះយើងគោរពថ្ងៃដែលយើងបានកសាងព្រះសហគមន៍សារជាថ្មី ថ្ងៃដែលព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា បានរស់ឡើងវិញ២៥ឆ្នាំកន្លងមក។ យើងនឹករឭកដល់ថ្ងៃដែលលោកអ៊ីវ និងលោកអេមីល នៅក្នុងឆ្នាំ១៩៨៩បានត្រឡប់មកវិញ យើងនឹកឃើញដល់ថ្ងៃបុណ្យចម្លង បុណ្យចូលឆ្នាំនៅឆ្នាំ១៩៩០ ដែលលោកអេមីល បានថ្វាយអភិបូជាលើកដំបូងសារជាថ្មីនៅក្នុងសាលចេនឡា។ យើងបាននឹកឃើញនៅឆ្នាំ១៩៩២ នៅពេលយើងបានទទួលកន្លែងនេះសារជាថ្មី លោកអ៊ីវ លោកអេមីល រួមជាមួយបងប្អូនគ្រីស្តបរិស័ទបានសម្អាត បានជួសជុល បានលាបថ្នាំ ឲ្យព្រះវិហារតូច ដើម្បីឲ្យទេវវិទ្យាយចាស់អាចប្រើបាន ឲ្យគ្រីស្តបរិស័ទអាចបន្តជួបជុំគ្នាជាមួយគ្នា៖ **ទីមួយ ដើម្បីអធិដ្ឋាន ទីពីរ ដើម្បីអប់រំជំនឿ និងទីបី ដើម្បីចែករំលែកធម៌មេត្តាករុណាដល់អ្នកក្រីក្រ។** យើងនឹករឭកដល់ប៉ុន្មានឆ្នាំដែលយើងបានមានមហាសន្និបាតទូទាំងប្រទេសនៅទីនេះ។ យើងនឹករឭកដល់ពេលវេលា ដែលកន្លែងនេះបានទៅជាក្រុងយេរូសាឡឹមយ៉ាងតូចនៅក្នុងប្រទេសកម្ពុជា ដោយសារទីកន្លែងដែលគ្រូអប់រំជំនឿបានចាប់ផ្តើមទៅដល់បាត់ដំបង ទៅកំពង់ចាម និងទៅដល់កន្លែងដាច់ស្រយាលនៃភូមិភាគភ្នំពេញ និងជាពិសេសនៅខេត្តកំពត និងខេត្តតាកែវ។ យើងនឹកឃើញដល់ពេលវេលា ដែលយើងបានមានអំណរសប្បាយដើម្បីប្រកាសដំណឹងល្អសារជាថ្មី ដោយសារពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៨៩ និង១៩៩០ ដំណឹងល្អដែលយើងបានទទួលជាទ្រព្យសម្បត្តិ យើងទុកតែនៅក្នុងដួងចិត្តរបស់យើង ដោយសារយើងគ្មានសេរីភាពដើម្បីប្រកាសដំណឹងល្អ។

ថ្ងៃនេះជាឱកាសមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់មែនសម្រាប់អ្វីៗទាំងអស់ដែលកើតឡើងពីព្រះវិហារផ្សារតូចនេះនៅក្នុង២៥ឆ្នាំកន្លងមក ដែលណែនាំឲ្យព្រះសហគមន៍របស់យើងទូទាំងប្រទេសមានជីវិតសារជាថ្មី។

ពិតមែនថ្ងៃនេះ យើងនៅក្នុងអំណរសប្បាយរួមជាមួយសន្តយ៉ូសែប ជាស្វាមីរបស់ព្រះនាងម៉ារី។ ថ្ងៃនេះ គឺជាថ្ងៃដែលយើងត្រូវតែមានកម្លាំងថ្មីដើម្បីនឹកឃើញដល់២៥ឆ្នាំខាងមុខ តើយើងជាព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច ព្រះសហគមន៍នៅភូមិភាគភ្នំពេញ ធ្វើអ្វីខ្លះដើម្បីបន្តប្រកាសដំណឹងល្អ ដើម្បីបន្តធ្វើជាអ្នកដែលអធិដ្ឋាននៅក្នុងទីក្រុងភ្នំពេញ។ អត្ថបទទីពីរថ្ងៃនេះថា **"បងប្អូនប្រៀបបាននឹងថ្មដែលមានជីវិត"**។ ២៥ឆ្នាំខាងមុខនេះ តើយើងធ្វើយ៉ាងម៉េចដើម្បីឲ្យយើងបង្ហាញថា ពិតមែនយើងជាថ្មដែលមានជីវិត ដើម្បីបន្តកសាងព្រះសហគមន៍របស់យើង ដើម្បីឲ្យព្រះសហគន៍របស់យើងជាព្រះសហគមន៍ដ៏មានជីវិត។

ខ្ញុំអញ្ជើញបងប្អូនទាំងអស់ ឲ្យសម្លឹងមើលព្រះនាងម៉ារី ហើយយើងនឹកឃើញដល់អាថ៌កំបាំងទាំងបួន៖ **អាថ៌កំបាំងនៃអំណរសប្បាយ អាថ៌កំបាំងនៃទុក្ខលំបាក អាថ៌កំបាំងនៃសិរីរុងរឿង និងអាថ៌កំបាំងនៃពន្លឺ។**

**អាថ៌កំបាំងនៃអំណរសប្បាយ** ជាពេលវេលាមួយដែលព្រះនាងម៉ារីបានទទួលដំណឹងល្អធ្វើជាមាតារបស់ព្រះជាម្ចាស់ ព្រះនាងម៉ារីទៅសួរសុខទុក្ខយាយអេលីសាប៊ែត ព្រះនាងម៉ារីបានឲ្យព្រះយេស៊ូប្រសូត និងដើម្បីសង្គ្រោះមនុស្សយើងទាំងអស់។ អាថ៌កំបាំងនៃអំណរសប្បាយ ជាពេលវេលាដើម្បីឲ្យយើងរួមជាមួយព្រះនាងម៉ារី រួមជាមួយព្រះយេស៊ូ យើងចូលយ៉ាងជ្រៅនៅក្នុងជីវិតប្រចាំនៃទីក្រុងភ្នំពេញ។ នេះជាបេសកកម្មដែលយើងទទួល ដើម្បីទៅជាផ្លូវតែមួយ អង្គតែមួយដូចព្រះយេស៊ូនៅក្នុង៣០ឆ្នាំនៅក្នុងភូមិ

ណាសារ៉ែត ដើម្បីឲ្យយើងយកចិត្តទុកដាក់ជាមួយបងប្អូននៅក្នុងជុំវិញព្រះសហគមន៍របស់យើងដូចពេលព្រះនាងម៉ារី បានចូលជ្រៅនៅក្នុងទឹកដីនៃប្រទេសអ៊ីស្រាអែល។

**អាថ៌កំបាំងនៃទុក្ខលំបាក** នឹកឃើញព្រះនាងម៉ារីដែលនៅក្បែរឈើឆ្កាង។ ព្រះនាងម៉ារីកំពុងយំ ដោយសារកូនជាទីស្រឡាញ់របស់ព្រះនាងកំពុងស្លាប់ ព្រះនាងម៉ារីដែលកំពុងបីព្រះយេស៊ូ។ ព្រះនាងម៉ារី ដែលប្រមូលទុក្ខលំបាកនៃពិភពលោកទាំងមូល នៃមនុស្សលោកទាំងមូលរួមជាមួយព្រះយេស៊ូនៅលើឈើឆ្កាង។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទនៅទីនេះ ជាពេលវេលាដើម្បីប្រមូលទុក្ខលំបាក ទុក្ខព្រួយ បញ្ហាទាំងឡាយ ដែលបងប្អូនឯទៀតៗមានសព្វថ្ងៃ នៅក្នុងទីក្រុងភ្នំពេញ នៅក្នុងក្រុមគ្រួសារ ជាមួយអ្នកជំងឺ ដើម្បីផ្ញើនូវទុក្ខលំបាកទាំងអស់ជាមួយព្រះយេស៊ូនៅលើឈើឆ្កាង តាមរយៈព្រះនាងម៉ារីនៅក្បែរឈើឆ្កាង។ ឲ្យយើងយល់ថាយើងរៀងៗខ្លួនត្រូវតែធ្វើ ដើម្បីបង្ហាញមេត្តាករុណា តាមសមត្ថភាពយើង ប៉ុន្តែដោយអស់ពីសមត្ថភាពដោយមានចិត្តមេត្តា ដោយទទួលស្វាគមន៍ជានិច្ច ជាពិសេសទុក្ខលំបាករបស់បងប្អូនឯទៀតៗ។

**អាថ៌កំបាំងនៃសិរីរុងរឿង** ជាពេលវេលាដើម្បីមើលព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូដែលឡើងស្ថានបរមសុខ ព្រះយេស៊ូដែលផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះនាងម៉ារីដែលឡើងស្ថានបរមសុខរួមជាមួយព្រះជាម្ចាស់ និងទទួលសិរីរុងរឿងស្មើនឹងព្រះយេស៊ូដែរ នេះជាជំនឿរបស់យើង នេះជាសេចក្តីសង្ឃឹមរបស់យើង។ អត្ថបទទីមួយថ្ងៃនេះថា **"ទីនេះជាកន្លែងសម្រាប់នាមយើង"** ទីនេះនៅផ្សារតូច ដើម្បីកោតសរសើរព្រះនាមរបស់ព្រះជាម្ចាស់ ជាពេលវេលាមួយដើម្បីបង្ហាញអំពីអំណរសប្បាយរបស់យើង សេចក្តីសង្ឃឹមរបស់យើង ជាពិសេសតាមរយៈការអធិដ្ឋាន តាមរយៈកោតសរសើរព្រះជាម្ចាស់។

**អាថ៌កំបាំងនៃពន្លឺ** សន្តយ៉ូហានប៉ូលទីពីរ បានបន្ថែមឲ្យព្រះសហគមន៍អធិដ្ឋានយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ និងព្រះនាងម៉ារីថែមទៀត។ នេះជាជីវិតនៃព្រះសហគមន៍! អាថ៌កំបាំងនៃពន្លឺជាជីវិតនៃព្រះសហគមន៍ ពិធីជ្រមុជទឹក មង្គលការ ពិធីកាច់នំប៉ុង ការប្រកាសដំណឹងល្អ និងព្រះរាជ្យព្រះជាម្ចាស់ ព្រះយេស៊ូដែលសម្តែងព្រះពន្លឺ សម្តែងឋានៈជាព្រះអង្គ ជាព្រះបុត្រាជាទីស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះសហគមន៍ផ្សារតូចជាកន្លែងមួយ ដើម្បីទទួលបងប្អូន ដើម្បីណែនាំបងប្អូនជាពិសេសឲ្យកូនៗរបស់បងប្អូនទទួលពិធីជ្រមុជទឹក និងទទួលជីវិតរួមជាមួយព្រះយេស៊ូ។ ជាពេលវេលាមួយដែរ ដើម្បីប្រកាសដំណឹងល្អ មិនមែនថែរក្សាជីវិតរបស់យើងខាងវិញ្ញាណរបស់យើងតែប៉ុណ្ណឹង ដើម្បីឲ្យយើងប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់ដោយអញ្ជើញបងប្អូនឯទៀតៗ ឲ្យគេស្គាល់ព្រះយេស៊ូគ្រីស្ត។

ខ្ញុំជឿថា នៅក្នុងបរិវេណរបស់ផ្សារតូច និងមណ្ឌលភ្នំពេញខាងជើងយើងមានកន្លែងយ៉ាងច្រើន ដើម្បីឲ្យយើងប្រកាសដំណឹងល្អថែមទៀត និងដើម្បីឲ្យយើងទៅជួបជាមួយបងប្អូនដែលកំពុងស្រេកឃ្លាន ដែលកំពុងទន្ទឹងរង់ចាំសេចក្តីសង្ឃឹមមួយ និងជួនកាលគេមិនដឹងទេសេចក្តីសង្ឃឹមរបៀបណា? ប៉ុន្តែនេះជាតួនាទីរបស់យើងជាគ្រីស្តទូតដែលព្រះយេស៊ូបានតែងតាំងយើងដើម្បីប្រកាសដំណឹងល្អថែមទៀត និងសារជាថ្មីទៀត។ ព្រះយេស៊ូមានព្រះបន្ទូលថា **"ខ្ញុំសូមប្រាប់អ្នកថា អ្នកឈ្មោះសិលា ហើយនៅលើផ្ទាំងសិលានេះ ខ្ញុំនឹងសង់ព្រះសហគមន៍របស់ខ្ញុំ"** ថ្ងៃនេះជាព្រះបន្ទូលសម្រាប់យើង។ នេះជាព្រះបន្ទូលសម្រាប់ខ្ញុំផ្ទាល់ សម្រាប់យើងរៀងៗខ្លួនផ្ទាល់។ យើងជាសិលា យើងនឹងសាងសង់ព្រះសហគមន៍នៅលើផ្ទាំងសិលានេះ មានន័យថាព្រះយេស៊ូទន្ទឹងរង់ចាំសង្ឃឹមលើយើង ដើម្បីកសាងព្រះសហគមន៍របស់ព្រះគ្រីស្ត។ យើងនឹកឃើញដល់មណ្ឌលអ្នកជំងឺ ដែលលោកអភិបាលអេមីលបានបង្កើតសារជាថ្មី នៅក្នុងឆ្នាំ១៩៩២ភ្លាមៗ ដើម្បីទទួលបងប្អូនដែលឈឺមកពីខេត្តនានា ឲ្យគេបានមកព្យាបាលក្នុងមន្ទីរពេទ្យនៅភ្នំពេញ។ យើងនឹកឃើញដល់ក្រុមយុវជន ដែលជាមួយលោក វីរៈជ័យ បានបង្កើតសកម្មភាពយ៉ាងច្រើន។

ដូច្នេះឲ្យយើងមានកម្លាំងកាយ កម្លាំងចិត្ត ឲ្យយើងមានជំនឿរឹងមាំ ឲ្យយើងឈរឡើង។ **គ្រីស្តបរិស័ទអើយ! ដើម្បីប្រកាស ពិតមែនយើងជាថ្មដែលមានជីវិត និងរួមគ្នា យើងចង់កសាងព្រះសហគមន៍របស់ព្រះគ្រីស្ត ដោយសារព្រះគ្រីស្តបានជ្រើសរើសយើងដូចព្រះយេស៊ូបានជ្រើសរើសលោកសិលា និងក្រុមគ្រីស្តទូតពីដើម ។**

នៅពេលនេះ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់២៥ឆ្នាំកន្លងមក យើងទូលអង្វរព្រះជាម្ចាស់សម្រាប់២៥ឆ្នាំខាងមុខនេះ ដោយទូលអង្វរព្រះនាងម៉ារីនៃទន្លេមេគង្គនៅអរិយ៍ក្សត្រ ដែលជួយមើលយើង ថែរក្សាយើងជានិច្ច។ យើងអរព្រះគុណព្រះជាម្ចាស់ ដោយទូលអង្វរព្រះអង្គធ្វើយ៉ាងម៉េច ដើម្បីឲ្យយើងបន្តកសាងព្រះសហគមន៍យ៉ាងស្អាត ដូចបងប្អូនបានសាងសង់អស់រយៈពេល២៥ឆ្នាំកន្លងមក។ **អាម៉ែន ៕**

# ឱកាសទទួលបានអាហារូបករណ៍សិក្សាថ្នាក់ បរិញ្ញាបត្ររង និងបរិញ្ញាបត្រ នៅវិទ្យាស្ថាន សន្តប៉ូល

## កម្មវិធីពិសេស



សម្រាប់ប្អូនៗសិស្សានុសិស្ស ដែលបានមកចុះឈ្មោះចូលរៀន ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ និងទទួលបានអាហារូបករណ៍ចាប់ពី ៥០%រហូតដល់ ១០០% ទាំងថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រ។





សូមកុំឱ្យឱកាសពិសេសនេះ
កន្លងហួសទៅឱ្យសោះ!
ឆមាសទី១ ចូលរៀននៅ
**ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧**

## បរិញ្ញាបត្ររង

- អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ
- គ្រប់គ្រង បណ្តាញកុំព្យូទ័រ
- ភាសាអង់គ្លេស
- សណ្ឋាគារ និងបដិសណ្ឋារកិច្ច
- ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ
- ជំនាញកែច្នៃអាហារ
- ប្រព័ន្ធកសិកម្មចម្រុះ

## បរិញ្ញាបត្រ

- ព័ត៌មានវិទ្យា
- អក្សរសាស្ត្រអង់គ្លេស
- គ្រប់គ្រងទេសចរណ៍
- គ្រូគ្រងសាស្ត្រ
- សង្គមកិច្ច


(៨៥៥) ៣២ ៦៣ ៩០ ០០២
(៨៥៥) ៣២ ៦៣ ៩០ ០០៣
(៨៥៥) ៩៦ ២៧ ៥១ ៥៦៨
spi.takeo@gmail.com
www.spi.edu.kh
ស្ថិតនៅភូមិអង្គគគីរ ឃុំតាភេម
ស្រុកត្រាំកក់ ខេត្តតាកែវ

## សកម្មភាពលោក អូលីវីយេ ស្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០១៧

១ វិច្ឆិកា ៖ ប្រជុំលោកអភិបាលទាំងបីភូមិភាគម៉ោង៣រសៀលនៅភ្នំពេញថ្មី

២-៤ វិច្ឆិកា ៖ សិក្ខាសាលាគ្រូអប់រំជំនឿអន្តរភូមិភាគនៅភ្នំពេញថ្មី

៩ វិច្ឆិកា ៖ ម៉ោង៩ព្រឹកខួប២៥ឆ្នាំវត្តមានរបស់ក្រុមបងស្រីសាឡេស៊ាននៅប្រទេសកម្ពុជា

១០ វិច្ឆិកា ៖ ប្រជុំអ្នកសម្របសម្រួលសេវាសុខភាពព្រះសហគមន៍ម៉ោង៨.៣០ព្រឹកនៅភ្នំពេញថ្មី

១១ វិច្ឆិកា ៖ ប្រសិទ្ធិពរលើជួងនៅព្រះសហគមន៍រោងចក្រ ប្រសិទ្ធិពរលើផ្ទះបងស្រីដូមីនីកាំងនៅមេគង្គ

១២ វិច្ឆិកា ៖ អភិបូជា និងសន្និបាតរបស់ក្រុមបេះដូងព្រះយេស៊ូនៅព្រះសហគមន៍ជ្រៃធំបាសាក់

១៣ វិច្ឆិកា ៖ បើកឆ្នាំសិក្សាថ្មីរបស់វិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ

១៤ វិច្ឆិកា ៖ ប្រសិទ្ធិពរសាលាមត្តេយ្យ និងបឋមសិក្សាថ្មីនៅកំពត

១៦ វិច្ឆិកា ៖ ប្រជុំទីប្រឹក្សាបេសកកម្ម

១៧-១៩ វិច្ឆិកា ៖ បូជនីសចររបស់យុវជននៅព្រះសហគមន៍គីរីវង់

២១ វិច្ឆិកា ៖ អភិបូជាប្រចាំខែនៅទេវវិទ្យាល័យ

២២ វិច្ឆិកា ៖ កម្មវិធីបើកសាលាសិល្បៈរបស់ El Nodo នៅព្រះសហគមន៍បឹងទំពុន

២៣ វិច្ឆិកា ៖ សិក្ខាសាលាក្រុមបូជាចារ្យ MEP ថ្មីៗ នៅតាកែវ

២៤ វិច្ឆិកា ៖ ប្រជុំក្រុម MEP

២៥ វិច្ឆិកា ៖ បង្រៀនទេវវិទ្យានៅសាលាអប់រំជំនឿសន្តយ៉ូស្ទីន

២៦ វិច្ឆិកា ៖ អភិបូជានៅអរិយក្សត្រ បុណ្យក្សត្រីព្រះនាងម៉ារីនៃទន្លេមេគង្គ

២៦ វិច្ឆិកា ៖ ស្វាគមន៍ក្រុមអូស្ត្រាលី

២៧-៣០ វិច្ឆិកា ៖ ក្រុមគ្រីស្តបរិស័ទតំណាងប្រទេសកម្ពុជាធ្វើដំណើរទៅប្រទេសភូមាដើម្បីជួបសម្តេចប៉ាប

## THE ACTIVITIES OF BISHOP OLIVIER SCHMITTHAEUSLER, MEP APOSTOLIC VICAR OF PHNOM PENH IN NOVEMBER 2017

1 Nov : Meeting with 3 bishops. 3pm. Phnom Penh Thmey

2-4 Nov : Seminar for catechists. Phnom Penh Thmey.

9 Nov : 25th anniversary of FMA - Teuk Thla. 9am

10 Nov : Health Services coordination. 8.30am. Phnom Penh Thmey

11 Nov : Blessing of Bells Tower - RongChak. Blessing of house of Dominican sisters. Mekong

12 Nov : Holy Mass and Sacred Heart Congress. Chrey Thom. Bassac

13 Nov : Opening new academic year. Saint Francois

14 Nov : Blessing New Kindergarten and Primary School. Kampot

16 Nov : Mission Council

17-19 Nov: Pilgrimage for Youths. Kirivong

21 Nov : Monthly mass at Major seminary

22 Nov : Opening ceremony of El Nodo School of arts. Boeung Toumpun.

23 Nov : MEP new priests seminar -Takeo

24 Nov : MEP Meeting

25 Nov : Teach Theology. Saint Justin School of faith

26 Nov : Holy mass. Areyksat. Our Lady of Mekong Feast

26 Nov : Catholic Mission Australia

27-30 Nov: Myanmar. Cambodian group meet with the Holy Father Francisco

# រូបភាពប្រចាំខែ


ក្រុមលោកអភិបាលឡាវ កម្ពុជា


អធិដ្ឋានពេញមួយយប់នៅទឹកថ្លា




អភិបូជានៅព្រះសហគមន៍សន្តហ្វ្រង់ស្វ័រ សាវីយេ៉ គង នយ


គ្រីស្តបរិស័ទរំឭកដល់អ្នកដែលស្លាប់

## វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជន សន្តហ្វ្រង់ស្វ័រ

ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជន សន្តហ្វ្រង់ស្វ័រ នឹងជ្រើសរើសសិស្សទាំងពីរភេទ ឱ្យសិក្សាផ្នែកជំនាញបច្ចេកទេសកសិកម្មរយៈពេលបីឆ្នាំស្របតាមកម្មវិធីសិក្សាស្តង់ដាររបស់ ក្រសួងអប់រំ យុវជន និងកីឡា។

### លក្ខខណ្ឌនៃការជ្រើសរើស

* ត្រូវមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (ឌីប្លូម ថ្នាក់ទី ១០)
* ត្រូវមានអាយុយ៉ាងតិច ១៥ ឆ្នាំគិតត្រឹមថ្ងៃចូលរៀន
* ត្រូវមានសីលធម៌ល្អក្នុងការរស់នៅ

### ការសិក្សា

* សិក្សាបច្ចេកទេសកសិកម្ម ២២ម៉ោង/សប្តាហ៍
* សិក្សាចំណេះដឹងទូទៅ ១៥ម៉ោង/សប្តាហ៍
* សិក្សាវិទ្យាសាស្ត្រកុំព្យូទ័រ ២ម៉ោង/សប្តាហ៍

### អត្ថប្រយោជន៍ដែលទទួលបាន

* ទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបច្ចេកទេស (បាក់ឌុប)
* អាចបន្តការសិក្សាទៅថ្នាក់ឧត្តមបាន
* ទទួលបានចំណេះ ជំនាញ បច្ចេកទេសកសិកម្មច្រើន











**ទីតាំង៖** ភូមិអង្គគគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ( ខាងក្រោយវិទ្យាស្ថាន សន្តប៉ូល)

**ទំនាក់ទំនង៖** ០១៧ / ០១៥ ៥៧៥ ៦៨៦ / ០១២ ៣១៤ ៤០៨ / ០៩០ ៩៩៣ ៣៩០

**ចំណាំ៖** សាលាក៏មានអន្តេវាសិកដ្ឋានសម្រាប់សិស្សមកពីឆ្ងាយស្នាក់នៅប្រកបដោយ សុវត្ថិភាព និងផាសុខភាព